DOCUMENT RESUME

ED 265 748 FL 015 492

TITLE	[Your New Life in the United States. Khmer Edition.]
INSTITUTION	Center for Applied Linguistics, Washington, D.C. Language and Orientation Resource Center.
PUB DATE	Apr 81
NOTE	222p.
PUB TYPE	Books (010) -- Guides - Non-Classroom Use (055)
LANGUAGE	Cambodian
EDRS PRICE	MF01/PC09 Plus Postage.
DESCRIPTORS	Acculturation; Adults; *Cambodians; *Daily Living Skills; *Immigrants; North American Culture; *Orientation Materials; Refugees

ABSTRACT

An illustrated guide to aspects of life in the United States is presented in Khmer for recent arrivals from Cambodia. The guidelines address such topics as resettlement agencies, community relations and national customs, the U.S. government, local and long distance transport, mail and telephone communication systems, employment practices, the educational system, types of housing, medical care, money and banking, taxation, insurance, consumer education and protection, and the legal and law enforcement systems. A directory of important national, local, and emergency telephone numbers is appended. (RW)

****
* Reproductions supplied by EDRS are the best that can be made *
* from the original document. *
****

ED265748

ជីវភាពថ្មី នៅ សហរដ្ឋអាមេរិក

U.S. DEPARTMENT OF EDUCATION
NATIONAL INSTITUTE OF EDUCATION
EDUCATIONAL RESOURCES INFORMATION CENTER (ERIC)

X This document has been reproduced as received from the person or organization originating it.

☐ Minor changes have been made to improve reproduction quality.

• Points of view or opinions stated in this document do not necessarily represent official NIE position or policy.

"PERMISSION TO REPRODUCE THIS MATERIAL HAS BEEN GRANTED BY
G Richard Tucker

TO THE EDUCATIONAL RESOURCES INFORMATION CENTER (ERIC)."

FL015442

ជីវភាពថ្មី នៅ សហរដ្ឋអាមេរិក

ចងក្រង និង ផលិតដោយ
មជ្ឈមណ្ឌលធ្វើការណែនាំ
មជ្ឈមណ្ឌលសំរាប់ភាសាអនុវត្តន៍

ប្រែ ប្រែសម្រួលជាភាសាខ្មែរដោយលោក ទេព ចុំង

©Copyright 1981
Center for Applied Linguistics
3520 Prospect St. NW
Washington DC 20007

ផ្នែកទី ១ : សេចក្តីផ្តើម

ផ្នែកទី ២ : ការធ្វើដំណើរនិងការទាក់ទងគ្នា

ផ្នែកទី ៣ : ការងារនៅក្នុងសហរដ្ឋអាមេរិក

ផ្នែកទី ៤ : អំពីការសិក្សា

ផ្នែកទី ៥ : អំពីលំនៅដ្ឋាន

ផ្នែកទី ៦ : ក្រសួងសង្គមកិច្ច

ផ្នែកទី ៧ : ការថែទាំសុខភាព

ផ្នែកទី ៨ : ហិរញ្ញវត្ថុនិងការអប់រំពីរបៀបប្រើប្រាស់

ផ្នែកទី ៩ : ច្បាប់នៅក្នុងសហរដ្ឋ

បញ្ជីរាយឈ្មោះ: អាស័យដ្ឋាន និង លេខទូរស័ព្ទ

អារម្ភកថា

សូមស្វាគមន៍ ដល់លោកអ្នកដែលចូលមកក្នុងសហរដ្ឋអាមេរិក។ ក្នុងឋានៈជាអ្នកភៀសខ្លួន ដែលទើបនឹងមកដល់ថ្មីក្នុងស្រុកនេះ លោកអ្នកប្រហែលជាមានសំណួរជាច្រើន ពីជីវភាពរស់នៅ ដូចជា: អំពីមនុស្សដែលលោកអ្នកនឹងជួបប្រទះ ការទទួលខុសត្រូវ ដែលលោកអ្នកត្រូវមាន និងពីប្រភេទជំនួយដែលលោកអ្នកអាចនឹងទទួល។ សៀវភៅនេះ បានប្រិតប្រៀង ដើម្បីនឹងជួយរកចំលើយ ទៅនឹងសំណួរខ្លះ ជាពិសេស នៅប៉ុន្មានខែមុនដំបូងនៃការតាំងទីលំនៅ។ ចំណងជើង ដែលលើកយកមកពិភាក្សា ចែកជាផ្នែក :

- សេចក្តីផ្តើម
- ផ្ទះសំបែង
- ការសិក្សា
- ការដឹកនាំនិងការទាក់ទងគ្នា
- ការងារ
- សង្គមកិច្ច
- ហិរញ្ញវត្ថុនិងការអប់រំពីរបៀបប្រើប្រាស់
- សុខភាព និងការថែទាំសុខភាព
- ច្បាប់

នៅខាងចុងបញ្ចប់នៃផ្នែកនីមួយៗ លោកអ្នកនឹងឃើញបញ្ជីកិច្ចការ ដែលលោកអ្នកត្រូវធ្វើ។ លោកអ្នកគួរប្រើបញ្ជីនេះ ដើម្បីសំរេចចិត្ត តើលោកអ្នកគួរដឹងនិងគួរធ្វើអ្វីខ្លះ នៅក្នុងរយៈប៉ុន្មានខែមុនដំបូង។ បើសិនជាលោកអ្នក ឬ សមាជិកណាមួយនៅក្នុងគ្រួសារ មានការពិបាកនឹងអានសៀវភៅនេះ ហើយមានថតជា កាសែត ពីពត៌មានសំខាន់ៗ នៅក្នុងសៀវភៅនេះ ដែលជួយឲ្យលោកអ្នកបានដឹងពីពត៌មានទាំងនេះ។ ពត៌មាននេះ ប្រើរូបថតជាគោល។ បើសិន

ជាលោកអ្នក មានអ្នកណាមួយក៏ អាចអានសៀវភៅ លោកនោះអាចអានឲ្យអ្នកឯទៀតស្តាប់ផង។

សៀវភៅនេះ រៀបចំឡើងដោយក្រុមអ្នកឯកទេសខាងផ្តល់ព័ត៌មាន ខ្មែរ ឡាវ ហ្មុង និងអាមេរិកាំង ដែលបានយល់ពីបញ្ហា និង ដំណើរការតាំងទីលំនៅ។ ក្រោយពីក្រុមនេះ បានពិភាក្សាជាមួយអ្នកភៀសខ្លួន និងអ្នកអាណាព្យាបាលជាច្រើន អានសៀវភៅផ្សេងៗដែលនិពន្ធឡើងដោយកម្មវិធីនៅក្នុងតំបន់នីមួយៗ និង និពន្ធដោយអង្គការជាតិ ក្រុមនេះក៏បានសរសេរជាសេចក្តីរៀបរាងមួយ ដែលអាចប្រាប់ព័ត៌មានសំខាន់ជាងគេ ពីជីវភាពរស់នៅ ក្នុងរយៈ ៤-៥ខែមុនដំបូង នៅក្នុងសហរដ្ឋ ដើម្បីឲ្យអ្នកភៀសខ្លួនបានយល់។ សៀវភៅនេះមានសរសេរជាភាសា ខ្មែរ ឡាវ ហ្មុង ចិននិងវៀតណាម។ ភាសាអង់គ្លេស មានសរសេរ ជាចំណែកនៃសៀវភៅសំរាប់អ្នកអាណាព្យាបាល។ ថ្វីត្បិតតែសៀវភៅនីមួយៗ ពិភាក្សាពីកម្មវត្ថុ (សាច់រឿង) ដូចគ្នា តែក៏មិនមែនដូចគ្នាលុទ្ធសាធនិងល្អិតល្អន់ ដូចគ្នានោះទេ។ ដូច្នេះ បើលោកអ្នកអានសៀវភៅខ្មែរ លោកអ្នកនឹងបានព័ត៌មានសំរាប់ជួយលោកអ្នកមកពីស្រុកខ្មែរ ឲ្យសំរួល (Adjust) មកតាមរបៀបសហរដ្ឋអាមេរិក។ បើលោកអ្នក អានសៀវភៅឡាវ លោកអ្នកនឹងដឹងព័ត៌មានពីអ្វី ដែលជនជាតិឡាវ អ្នកអាណាព្យាបាល និងអង្គការសង្គមកិច្ច យល់ថា មានសារៈសំខាន់សំរាប់ឡាវ ដែលសំរួលទៅតាមជីវភាពថ្មី។

ជាការធម្មតា មិនដែលមានសៀវភៅណា អាចឆ្លើយនឹងសំនួរទាំងអស់ទេ។ សៀវភៅនេះ ក៏គ្មានគោលបំណងដូច្នេះដែរ។ វាគ្រាន់តែផ្តល់ចំណុចសំខាន់ៗ ដែលសំរាប់ចាប់ផ្តើមនឹងជួយ នាំទៅរកប្រភពព័ត៌មានផ្សេងៗទៀត។ លោកអ្នកគួរតែអានឲ្យបានដឹងច្បាស់ ពីព័ត៌មាននិងន័យនៅក្នុងសៀវភៅនេះ ហើយពិភាក្សាជាមួយមិត្ត និងអ្នកអាណាព្យាបាល និងអ្នកឯទៀតៗនៅក្នុងសហគមន៍ ដើម្បីបានព័ត៌មានបន្ថែមនឹងន័យពិតតែបានយល់ច្បាស់ ពីរបៀបដែលជនជាតិនៅស្រុកនេះធ្វើកិច្ចការ។ លោកអ្នកនឹងមានសំនួរជាច្រើន ដែលត្រូវការចម្លើយ ហើយក៏មានមនុស្សជាច្រើនដែរ ដែលអាចជួយផ្តល់ចម្លើយ។

ហេតុបានចងក្រងព័ត៌មាន នៅក្នុងសៀវភៅនេះ សំរាប់ប្រើជាទូទៅនៅក្នុងសហរដ្ឋ។ ទោះជាយ៉ាងណាក៏

ដោយ នៅពេលអានសៀវភៅនេះ លោកអ្នកនឹងមានការកត់សំគាល់ ពីរបៀបខុសគ្នាជាច្រើន ដែលមនុស្សធ្វើកិច្ចការ និងកិច្ចការបំរើ(Services) ដែលមាននៅក្នុងប្រទេសនេះ។ លោកអ្នកនឹងត្រូវការស៊ើបសួរ ពីធនាគារ ឬ កិច្ចការសំរាប់បំរើ ដែលមាននៅក្នុងតំបន់លោកអ្នករស់នៅ។ អ្នកអាណាព្យាបាល សមាគមខ្មែរ មិត្ត ឬ អ្នកផ្តល់កិច្ចការបំរើនៅក្នុងសហគមន៍ ជាអ្នកដែលអាចជួយបំភ្លឺ និង ណែនាំពីការស្មុគស្មាញ ក្នុងជីវភាពថ្មី។

ថ្វីត្បិតតែសៀវភៅនេះចងក្រងសំរាប់មនុស្សចាស់ សំរាប់ប្រមុខគ្រួសារ តែសៀវភៅនេះមានផ្តល់ពត៌មានសំខាន់ៗ ទៅអ្នកឯទៀតក្នុងគ្រួសារដែរ។

មានមនុស្សជាច្រើន ដែលយកចិត្តទុកដាក់យ៉ាងខ្លាំង ចំពោះគំរោងការណ៍ ហើយដែលបានចំណាយពេលវេលាធ្វើអត្ថាធិប្បាយ ដើម្បីធ្វើអោយសៀវភៅនេះ មានសារៈប្រយោជន៍ជាអតិបរមា។ មានមនុស្សជាច្រើន ដែលយើងត្រូវសំដែងអំណរគុណនៅកន្លែងនេះ។

គ្រូបង្រៀនជនជាតិអាស៊ីជាច្រើន បានដាស់តឿនជានិច្ច ពីច្បាប់ទូទៅនៃរៀនសូត្រ ៣យ៉ាង :

រៀន - សំនួរ　　　　　　រៀន - សួរ
រៀន - ការហាត់ធ្វើ　　ឬ　　រៀន - សាកធ្វើ
រៀន - ការអនុវត្តន៍　　　　　រៀន - អនុវត្តន៍

យើងមិនអាចស្នើ ពីរបៀបប្រសើរណាមួយ អោយប្រើសៀវភៅនេះទេ។ យើងសង្ឃឹមថា ប្រមុខគ្រួសារ អ្នកអាណាព្យាបាល និងអ្នកផ្តល់កិច្ចការបំរើ នឹងធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធ ក្នុងការប្រើសៀវភៅនេះ។ អ្នកទាំងនេះ ត្រូវបង្រៀនលោកអ្នកជាច្រើន តែចូរចាំទុកថា លោកអ្នកក៏ត្រូវបង្រៀនអ្នកទាំងនោះវិញដែរ។

បើពិតជាលោកអ្នកត្រូវការពត៌មានបន្ថែម ឬ ជំនួយ ក្នុងការរកពត៌មាន លោកអ្នកអាចទូរស័ព្ទរកបុគ្គលិកមជ្ឈមណ្ឌលធ្វើការណែនាំ អោយជួយ តាមធម្មតា តែងមានអ្នកធ្វើការជាតិខ្មែរ និយាយឆ្លងឆ្លើយជាមួយលោកអ្នក។

មជ្ឈមណ្ឌលធ្វើការណែនាំ (Orientation Resource Center)

មជ្ឈមណ្ឌលភាសាអនុវត្តន៍ (Center For Applied Linguistics)

3520 Prospect St.,N.W

Washington , D.C. 20007

(202)298-9292

(800)424-3701

សេចក្ដី ផ្ដើម

បញ្ជីអត្ថបទ

ការតាំងទីលំនៅក្នុងសហរដ្ឋអាមេរិក..............៣
អ្នកអាណាព្យាបាល..........................៤
ជីវិតថ្មីនៅក្នុងសហរដ្ឋអាមេរិក...................៥
ទំនាក់ទំនងនៅក្នុងសហគមន៍....................៦
អតីសាសនានៅក្នុងសហរដ្ឋអាមេរិក............៧-៨
ទំនៀមទំលាប់និងចរិតអាមេរិកាំង...............៩
ការជំរាបសួរ...........................៩
ឈ្មោះ..................................១០
ពេលវេលា.............................១០
កាយវិការ.............................១១
គ្រួសារអាមេរិកាំង.......................១២
ការកំសាន្ត.............................១២
រដ្ឋាភិបាលអាមេរិកាំង.......................១៣
រដ្ឋាភិបាលជនបទ.........................១៣
រដ្ឋាភិបាលរដ្ឋ...........................១៤
រដ្ឋាភិបាលសហពន្ធ........................១៤

ការតាំងទីលំនៅក្នុងសហរដ្ឋអាមេរិក

នៅក្នុងសហរដ្ឋអាមេរិក អង្គការស្ម័គ្រចិត្តនិងមនុស្សធម៌ ដែលហៅថា "វ៉ូឡាគ VOLAG" ទទួលចាត់ចែងមួយផ្នែកយ៉ាងធំ ក្នុងការតាំងទីលំនៅជនភៀសខ្លួន។ អង្គការទាំងនេះ បានចុះកិច្ចសន្យាជាមួយរដ្ឋាភិបាល ទទួលខុសត្រូវ ក្នុងការចាប់ផ្ដើមតាំងទីលំនៅ ឲ្យជនភៀសខ្លួន។ គឺជាក្រុមឯកជន ឥតយកកំរៃ ហើយដែលភាគច្រើន

ជាសាខារបស់សាសនា។

អង្គការ VOLAG នេះ ជួយធ្វើគំរោងផ្ទាល់ខ្លួនទីលំនៅ និងគំរោងកិច្ចការសង្គមកិច្ច។ ក្រុមនេះជួយដើរការ យកគ្រួសារពីជំរុំនិងពីស្រុកកំណើត ឲ្យមកជួបជុំនឹងគ្រួសារ ដែលបានមករស់នៅក្នុងសហរដ្ឋរួចមកហើយ។ អង្គការស្ម័គ្រចិត្តទាំងនេះ មានការិយាល័យនៅក្នុងសហគមន៍តាមតំបន់ សំរាប់ទទួលធ្វើកិច្ចការទាំងនេះ និង ទាក់ទងផ្ទាល់នឹងអ្នកភៀសខ្លួន។ សូម្បីតែនៅក្នុងក្រុម ឬ អង្គការតែមួយជាមួយគ្នា ក៏ដោយ ក៏បន្ទាត់នយោបាយ និងការអនុវត្តន៍ ខុសគ្នាពីតំបន់មួយទៅតំបន់មួយទៀត ជួនកាលតិច ជួនកាលច្រើន។ របៀបផ្ដល់ជំនួយ ព្រមទាំងចំនួនទានអំពីជំនួយប្រាក់កាស (Financial assistance) ជំនួយម្ហូបអាហារ និងថ្នាំសង្កូវ ក៏អាចខុសគ្នា ពីការិយាល័យមួយទៅការិយាល័យមួយទៀតដែរ។ នៅពេលលោកអ្នកមកដល់សហរដ្ឋ ការិយាល័យខ្លះ អាចផ្ដល់ប្រាក់កាសខ្លះ ដល់លោកអ្នក ការិយាល័យខ្លះទៀតអាចឲ្យតែបន្តិចបន្តួច ឬអត់សោះតែម្ដង។ ប៉ុន្តែគេផ្ដល់ជំនួយកិច្ចការផ្សេងទៀត។ ដូច្នេះ ជាការសំខាន់ ដែលលោកអ្នកធ្វើការទាក់ទងជាប់ជានិច្ច ជាមួយក្រុមអង្គការវ៉ូឡាគទាំងនេះ ដើម្បីឲ្យបានយល់ច្បាស់ពីជំនួយផ្សេងៗដែលគេអាចផ្ដល់ឲ្យ។ បើចង់បានពត៌មានបន្ថែមសូមអានជំពូកទី៥ៈ "ក្រសួងសង្គមកិច្ច"។

អ្នកអាណាព្យាបាល

អ្នកអាណាព្យាបាល ជាមនុស្ស(ឬអង្គការ) ស្ម័គ្រចិត្ត ដែលបានចំណាយពេលវេលានិងធនធាន ដើម្បីនឹងជួយគ្រប់គ្រង ឲ្យលោកអ្នកចាប់ផ្តើមកសាងជីវិតថ្មី នៅក្នុងសហរដ្ឋ។ ជនជាតិអាមេរិកាំងភាគច្រើន តែងបានគិតថា ខ្លួនបានធ្វើកិច្ចពិសេសមួយ ក្នុងនាមជាអ្នកអាណាព្យាបាល ទទួលយកអ្នកភៀសខ្លួនពីទីកន្លែងផ្សេងៗ ក្នុងសកលលោក។ គំនិតជួយអ្នកដទៃ ជាលក្ខណៈមួយ របស់ប្រជារាស្ត្រអាមេរិកាំង។ អ្នកអាណាព្យាបាលភាគច្រើន មានបំណងល្អចង់ជួយ ថ្វីបើគេមិនសូវដឹង ពីវប្បធម៌របស់យើងក៏ដោយ ក៏គេនៅតែជួយផ្គត់ផ្គង់ ដល់រូបលោកអ្នកដែរ។

អ្នកអាណាព្យាបាល នឹងជួយផ្គត់ផ្គង់ម្ហូប កន្លែងរស់នៅបណ្ដោះអាសន្ន ដើម្បីឲ្យលោកអ្នក ចាប់ផ្តើមការរស់នៅមុនដំបូងនៅសហរដ្ឋ។ គេអាចជួយរកការងារឲ្យលោកអ្នកធ្វើ ជួយចុះឈ្មោះឲ្យកូនទៅរៀន បង្ហាត់ឲ្យចេះរបៀបទិញអីវ៉ាន់ នឹកនាំឲ្យជួបជាមួយអ្នកជិតខាង និងបង្ហាត់ឲ្យចេះជិះឡានបឺសជាដើម។ ជួនកាល គេជួយរកអ្នកផ្សេងទៀត ឲ្យមកជួយបន្ថែម។ បន្ទាប់ពីនេះមក គេសង្ឃឹមថា លោកអ្នកនឹងអាចធ្វើកិច្ចការទាំងនេះ និងអាចរស់នៅដោយខ្លួនឯង។

ការទទួលធ្វើអាណាព្យាបាល ជាករណីយកិច្ចខាងគុណធម៌តែប៉ុណ្ណោះ មិនមែនជាបំណងឬតំរូវពីផ្លូវច្បាប់ទេឡើយ។ រយៈពេលនិងរបៀបអាណាព្យាបាលខុសៗពីគ្នា ទៅតាមមនុស្ស ទៅតាមអង្គការ។ ជនខ្លះឬអង្គការខ្លះ មានពេលនិងធនធានច្រើនជាងអង្គការឯទៀតៗ ហើយចំនួនអ្នកភៀសខ្លួននៅកន្លែងនីមួយៗ អាចធ្វើឲ្យប្រែប្រួល ដល់ចំនួននិងធនធានអ្នកអាណាព្យាបាល។

ជីវិតថ្មីនៅក្នុងសហរដ្ឋអាមេរិក

ការតំរូវទៅតាមវប្បធម៌ថ្មី ទំនៀមទំលាប់ថ្មី និងការរស់នៅថ្មី មុនដំបូងជាការមួយពិបាកៗ នៅពេលដែលកំពុងធ្វើការសំរបសំរួល តាមធម្មតា មនុស្សម្នាក់ៗតែងឆ្លងកាត់ច្រើនដំណាក់ៗ មុនដំបូង លោកអ្នកអាចភ្ញាក់ផ្អើលនឹងការរស់នៅថ្មី ក្នុងសហរដ្ឋៗ នៅពេលដែលលោកអ្នកចេញដំណើរមកដល់សហរដ្ឋ លោកអ្នកច្បាស់ជាមានការរំភើប ហើយហាក់ដូចជាធ្វើឲ្យលោកអ្នកមានកម្លាំងប្លែកក្រោយពីការរង់ចាំ អស់ចំនួនជាច្រើនខែនៅក្នុងជំរុំមកៗ អ្នកអាណាព្យាបាលក៏មានការរំភើប ហើយសប្បាយដែរនៅពេលដែលគេបានឃើញ និងជួបអ្នកភៀសខ្លួន ដែលគេធ្វើអាណាព្យាបាលមកដល់ៗ ក៏ប៉ុន្តែ ជួនកាល ការសប្បាយរបស់អ្នកទាំងពីរ អាចធ្លាប់រលត់បាត់ទៅវិញ ដោយសារការពិបាកច្រើនប្រការ ទាំងខាងភ័ស្តុភារ ទាំងខាងផ្លូវចិត្តៗ អ្នកភៀសខ្លួន និងអ្នកអាណាព្យាបាល នឹងត្រូវបានជួបប្រទះការពិបាកនេះៗ នេះជារយៈកាលធុញថប់ និងមានសភាពតានតឹងបំផុតៗ មុនដំបូង អ្នកអាណាព្យាបាលក៏មានការពិបាកនឹងតម្របទៅតាមវប្បធម៌ ឬ របៀបរស់នៅរបស់អ្នកភៀសខ្លួនខ្មែរយើង ដូចគ្នានឹងអ្នកភៀសខ្លួនខ្មែរយើង មានការពិបាកនឹងការរស់នៅ ឲ្យស្របតាមបែបរបៀបអាមេរិកាំងអញ្ចឹងដែរៗ

ទំនាក់ទំនងនៅក្នុងសហគមន៍

សហរដ្ឋអាមេរិក ជាប្រជាជាតិដែលកើតឡើងដោយជនភៀសខ្លួននិងជនអន្តោប្រវេសន៍ៗ មានតែជនជាតិស្បែកក្រហម "អាមេរិកាំងឥណ្ឌាន" ទេ ដែលជាជនជាតិអាមេរិកាំង ពីដើមកំណើតស្រាប់ ហើយដែលបានរស់នៅលើទឹកដីនេះតាំងពីមុនជនជាតិអឺរ៉ុបមកដល់ៗ ថ្វីត្បិតតែគេហៅសហរដ្ឋអាមេរិកថា "ម៉ុលធីងផត" (Melting pot) "ឆ្នាំងសំរាប់រំលាយ" បានន័យថា ជាកន្លែងដែលជនជាតិច្រើនសាសន៍បានរស់នៅលាយឡំគ្នា ។ ក្រុមជាច្រើនដែលមករស់នៅ បានរក្សាទុកទំនៀមទំលាប់ដើម ភាសានិងប្រពៃណីដើមៗ ការខុសគ្នានេះ បានធ្វើឲ្យវប្បធម៌អាមេរិកាំងល្អណាស់ និងជាទីចាប់អារម្មណ៍ៗ នៅទីក្រុងធំៗ លោកអ្នកអាចឮគេនិយាយភាសាចិន កូរ៉េនិងស្ប៉ាញ៉ុលៗ លោកអ្នកអាចទៅភោជនីយដ្ឋានអ៊ីស្រាអែល ទៅទិញអីវ៉ាន់នៅផ្សារចិន និងទៅទស្សនាភាពយន្តបារាំងៗ ការដែលជនជាតិអាមេរិកាំងអាចទទួលទំនៀមទំលាប់ថ្មីទៅបាន ដោយសារវត្តមាននៃក្រុមសហគមន៍ចំរុះគ្នាច្រើនៗ

ចំពោះមនុស្សភាគច្រើន ការទាក់ទងក្នុងសហគមន៍ជាផ្នែកមួយសំខាន់របស់ជីវិតអាមេរិកាំងៗ សហគមន៍នេះអាចកើតឡើង ដោយជនជាតិមួយក្រុម ដោយក្រុមសាសនា ឬដោយក្រុមដែលមានផលប្រយោជន៍រួមគ្នាៗ ក៏ប៉ុន្តែ ការ
ង

តានតឹង តែងកើតមានឡើងជានិច្ច នៅពេលដែលមានអ្នកចំណូលថ្មីៗ នៅពេលដែលមានជនអន្តោប្រវេសន៍ឬ ជនភៀសខ្លួនច្រើន ចូលមកនៅក្នុងសហគមន៍ ដូចជា រដ្ឋ ទីក្រុង ផ្សារ ឬ ភូមិ ការតានតឹងអាចកើតមានឡើងៗ ការតានតឹងនេះ អាចបណ្តាលមកពីហេតុផលជាច្រើន ដូចជា:

- ពូជសាសន៍ឬសញ្ជាតិ
  ដើមកំណើតៗ
- ស្ថានភាពសេដ្ឋកិច្ចៗ



នៅក្នុងសហគមន៍ខ្លះ ការតានតឹងអាចកើតឡើង ដោយក្រុមមួយមានការបារម្ភ ពីក្រុមថ្មីមកដណ្ដើមជួលផ្ទះ ឬដណ្ដើមការងារ។ ក្រុមផ្សេងទៀត អាចភ័យឬអាក់អន់ចិត្ត ពីក្រុមដែលមានជំនឿនយោបាយនិងសាសនាខុសគ្នា។ អ្នកដែលគ្មានគ្រួសារ ធ្លាប់រស់នៅម្នាក់ឯងក្នុងផ្ទះបន្ទប់ អាចខឹងសម្បារ ដោយឃើញគ្រួសារមានគ្នាច្រើន មករស់នៅជិត ដោយខ្លាចគ្រួសារទាំងនេះ ធ្វើឱ្យឡូឡាឥតឈប់ឈរ។

ការដែលមិនយល់ឬមិនចេះនិយាយភាសាបរទេស ឬមិនចេះរបៀបធ្វើអ្វីផ្សេងៗ អាចបណ្ដាលឱ្យមានការពិបាកក្នុងការទាក់ទងគ្នា រវាងអាមេរិកាំងនិងអ្នកមកដល់ថ្មី។ ការពិបាកក្នុងការទាក់ទងគ្នានេះ អាចធ្វើឱ្យការតានតឹង ការមិនចូលចិត្តឬការស្អប់ខ្ពើមគ្នា កើតមានឡើង។ ការតានតឹងនេះ ក៏អាចកើតឡើង រវាងអាមេរិកាំងគ្នាឯងដែរ ហើយសូមលោកអ្នកកុំគិតថា ការតានតឹងទាំងនោះ ជាកំហុសរបស់លោកអ្នក។ បើមានបញ្ហាកើតឡើង ចូរលោកអ្នកកុំរារែក និងរកសមាគមខ្មែរ អង្គការស្ម័គ្រចិត្ត និងភ្នាក់ងារតម្រួត ប៉ូលិស ឱ្យជួយ។

អំពីសាសនានៅក្នុងសហរដ្ឋអាមេរិក

សេរីភាពក្នុងជំនឿ ជាគ្រឹះមួយផ្នែកនៃជីវិតជនជាតិអាមេរិកាំង។ ឥតមានព្រះវិហារមួយណារបស់អាមេរិកាំង ជាផ្លូវការទេឡើយ ហើយប្រជារាស្ត្រ អាចកាន់ជំនឿរបស់ខ្លួនដោយសេរី។ នៅសហរដ្ឋ លោកអ្នកអាចឃើញ ព្រះវិហារគ្រិះ ព្រះវិហារព្រះពុទ្ធ ព្រះវិហារឥស្លាម ព្រះវិហារជូវអ៊ីស្ហ(Jewish)

នៅតំបន់ភាគច្រើន ដែលមានអ្នកភៀសខ្លួនច្រើនរស់នៅ អាចមានព្រះវិហារដែលមានបព្វជិត មកពីស្រុកកំណើតដូចគ្នា។ នៅពេលមានពិធីបុណ្យសំខាន់ៗ សមាជិកក្រុមសាសនា និងសមាគម នាំគ្នាប្រជុំនៅព្រះវិហារទាំងនេះ ដើម្បីនិងធ្វើបុណ្យ ធ្វើសកម្មភាពផ្សេងៗ ផ្សេងពីនេះ ក្រុមសាសនានិងសមាគមទាំងនេះ អាចធ្វើជាអ្នកជួយឧបត្ថម្ភប្រជាមស្រែជង ការតាំងទីលំនៅរបស់លោកអ្នក។ ក្រុមទាំងនេះ អាចជួយផ្ដល់ម្ហូប ខោអាវនិងកិច្ចការផ្សេងៗ ឬអាចនាំលោកអ្នក ឱ្យទាក់ទងនឹងកន្លែងផ្ដល់ជំនួយនិងកិច្ចការផ្សេងៗ នៅក្នុងសហគមន៍។

ជាទូទៅ កន្លែងដែលស្រួលជាងគេសំរាប់បន់ស្រន់ ឬសំពះព្រះជាមួយគ្រួសារគឺ នៅក្នុងផ្ទះ។ បើសិនជាចាំបាច់ត្រូវធ្វើពិធីបុណ្យធំៗ មជ្ឈមណ្ឌលរបស់សមាគមឬសាលា ជួន



កាល អាចផ្តល់ទីកន្លែង សំរាប់ប្រជុំគ្នា។ មុននឹងធ្វើពិធីផ្សេងៗ ជាការល្អ គួរពិគ្រោះនឹងអ្នកអាណាព្យាបាល ឬ មិត្ត ព្រោះអ្វីៗដែលយើងធ្លាប់ធ្វើនៅស្រុកខ្មែរ អាចខុសនឹងច្បាប់នៅសហរដ្ឋ មកពីប្រការផ្សេងៗ ដូចជា សុខភាព អនាម័យ ឬ សន្តិសុខ ឧ. ដូចជាគេមិនឲ្យដុតធូប ឬ ទៀននៅក្នុងមន្ទីរពេទ្យ។ នៅរដ្ឋភាគច្រើន បុណ្យខួបត្រូវធ្វើនៅផ្ទះសំរាប់ដំកល់ខ្មោច របស់អាមេរិកាំង ។

មានកាលៈទេសៈខ្លះ គេអាចអញ្ជើញលោកអ្នក ទៅចូលរួម ពិធីបុណ្យសាសនា របស់អ្នកអាណាព្យាបាល ឬ មិត្ត អាមេរិកាំង។ លោកអ្នកអាចទៅចូលរួម បើលោកអ្នកចង់ដឹង ឬក៏មិនទៅក៏បាន ដោយគ្មានការបង្ខិតបង្ខំអ្វីឡើយ។ បើលោកអ្នកមិនចង់ទៅ លោកអ្នកគ្រាន់តែឆ្លើយថា : "ទេ សូមអរគុណ" No ,Thank you។

ទំនៀមទំលាប់និងចរិយាអាមេរិកាំង

ការស្ញើយឆ្លងទាក់ទងជាមួយអាមេរិកាំង តែងមានការពិបាក នៅពេលចាប់ផ្ដើម។ នេះជាការធម្មតា សំរាប់មនុស្សដែលរស់នៅក្នុងវប្បធម៌មួយ ហើយមានការពិបាកក្នុងការគិត ឬ ស្ដាប់ពីរបៀបធ្វើអ្វីផ្សេងៗក្នុងវប្បធម៌មួយទៀត ថាខុសឬត្រូវ។ ក្នុងការជួបប្រទះនឹងវប្បធម៌អាមេរិកាំងលើកដំបូងបែបនេះ លោកអ្នកត្រូវសាកល្បងឲ្យបានស្គាល់ជិតដិត នឹងទំនៀមទំលាប់និងចរិយាសិន។

ជនជាតិអាមេរិកាំង ជាទូទៅ ចូលចិត្តរាក់ទាក់ រួសរាយ និងជាធម្មតា ដែលគេជឿថា ជាសញ្ញាមិត្តភាព។ ការជំរាបសួរ និងការហៅចំឈ្មោះផ្ទាល់ខ្លួន ជាសញ្ញាមួយដ៏ធំនូវការរាក់ទាក់នេះ។

ការជំរាបសួរ

ជនជាតិអាមេរិកាំង ជំរាបសួររបៀបស្និទ្ធស្នាលធម្មតា លើកលែងតែគេជួបអ្នកណាម្នាក់លើកទី១ ឬនៅពេលជាផ្លូវការ។ ជនជាតិអាមេរិកាំងមិនដែលឱនក្បាលទៅវិញទៅមកទេ។ នៅពេលដែលនាំឲ្យស្គាល់គ្នាមុនដំបូង គេតែងនិយាយដាក់គ្នាទៅវិញទៅមកថា: "ជំរាបសួរ" ឬ "ខ្ញុំសប្បាយនឹងជួបលោក"។ បន្ទាប់ពីនោះមក គេនឹងគំនាប់គ្នារបៀបស្និទ្ធស្នាលបន្តិចទៅវិញ ដូចជា "សុខសប្បាយឬទេ" ឬ "សុខទុក្ខយ៉ាងម៉េចដែរ" ឬក៏ញញឹមរបៀបគួរសម ហើយនិយាយថា "ហេឡូ" (Hello) តែប៉ុណ្ណោះបានស្រេច។

ឈ្មោះ(Name)

អាមេរិកាំងជាច្រើន ប្រើឈ្មោះក្រៅផ្លូវការខ្លី ជំនួសឈ្មោះផ្លូវការវែងៗ។ ន.អ្នកខ្លះឈ្មោះ "សាមូអែល ចនសុន" មិត្តគេហៅតែ "សាម"។ អ្នកខ្លះទៀតឈ្មោះ "រីឆាដ ព្រោន" ចង់ឲ្យគេហៅខ្លួនថា "ឌិក" ទៅវិញ។ ឈ្មោះ "បាប៊ីរ៉ា វែល្ស" ចង់ឲ្យគេហៅថា "បប៊ី" ទៅវិញ។ អាមេរិកាំង យកឈ្មោះជីតាមកដាក់ខាងក្រោយ។ ន.ចន ស្មីត ស្មីត ជាឈ្មោះជីតា។ នៅពេលប្រើជាផ្លូវការ ឬ ជួបអ្នកណាម្នាក់លើកទី១ លោកអ្នកគួរហៅឈ្មោះជីតា ដោយដាក់ "មិស្ទ័រ" ខាងមុខ ដូចជា Mr.Smith ។ សូម្បីមនុស្សដែលមិនធ្លាប់ស្គាល់លោកអ្នកជិតដិតក៏ដោយ ជាញឹកញាប់គេហៅឈ្មោះផ្ទាល់ខ្លួនរបស់លោកអ្នក។ នេះជាទម្លាប់ធម្មតារបស់អាមេរិកាំង។ អាមេរិកាំងគិតថា ការប្រើឈ្មោះផ្ទាល់ខ្លួន គឺជាការសំដែងមិត្តភាពស្និទ្ធស្នាល និងងាយស្រួលជាង។

ពេលវេលា

អាមេរិកាំងគេចែកពេលវេលាជាពេលដាច់ៗគ្នា ហើយគ្រោងធ្វើសកម្មភាពផ្សេងៗគ្នា។ អាមេរិកាំងប្រើពេលទៀងម៉ោង បើគេសន្យាម៉ោង ៨ គេនឹងចាប់ផ្ដើមម៉ោង ៨។ បើសន្យាថា ជួបគ្នា ហើយអ្នកទៅដល់យឺត១៥នាទី ដោយគ្មានហេតុផលនោះ នឹងធ្វើឲ្យគេខឹងសម្បារ។ បើលោកអ្នកសង្ស័យថា លោកអ្នកទៅដល់យឺត ត្រូវទូរស័ព្ទទៅប្រាប់គេជាមុន ហើយឲ្យគេដឹងពត៌មានអំពីការយឺតនេះ។ បើសិនជាលោកអ្នកមកដល់យឺត លោកអ្នកត្រូវសុំទោស ហើយប្រាប់គេមកពីហេតុផលអ្វី។ បើមានការណាត់ជួបនឹងលោកវេជ្ជបណ្ឌិត ត្រូវមកឲ្យទាន់ម៉ោង។ លោកវេជ្ជបណ្ឌិតអាចឲ្យលោកអ្នករង់ចាំ ប៉ុន្តែបើលោកអ្នកទុកឲ្យលោកវេជ្ជបណ្ឌិតរង់ចាំ ដោយមិនបានប្រាប់ជាមុន គេអាចឲ្យលោកអ្នកបញ្ញលុយពេលដែលលោកវេជ្ជបណ្ឌិតរង់ចាំលោកអ្នក។

កាយវិការ

កាយវិការ(ប្រើដៃឬផ្នែកផ្សេងៗដើម្បីជាសញ្ញា)ជាផ្នែកមួយនៃវប្បធម៌ៗ អ្វីដែលជាការគួរសមសំរាប់ជាតិមួយ អាចទៅជាការគ្រោតគ្រាតរបស់ជាតិមួយទៀតៗ ឧ.អាមេរិកាំងប្រើម្រាមដៃតែមួយទៀងលើ បក់ហៅឲ្យគេមករកខ្លួនៗ មិនតែប៉ុណ្ណោះ អ្នកខ្លះបះ ឬលាប ដូចជាដាក់ដៃលើស្មា ឬអោបស្មា ដើម្បីបញ្ចេញភាពកក់ក្ដៅៗ ជួនកាលគេកាន់ដៃលោកអ្នក ដើម្បីជួយចម្លងផ្លូវៗ បើសិនជាលោកអ្នក មានការមិនស្រួលចិត្ត លោកអ្នកអាចដកដៃចេញដោយគួរសម ដោយមិនឲ្យអ្នកនោះចាប់អារម្មណ៍ខុសៗ អាមេរិ-កាំងប្រើនអោបមិត្ត នៅពេលដែលគេជួបគ្នាៗ សូមលោកអ្នកកុំធ្វើតាមកាយវិការនេះ បើមិនយល់ច្បាស់ពីន័យនៃកាយវិការទាំងនេះទេៗ ការស្រលាញ់រាប់អាន ដោយប្រើកាយវិការ ដែលឃើញតែច្រើនតាមរបៀបខ្មែរយើង អាចចាត់ទុកថា ជាការមិនសូវគួរសម ចំពោះជនជាតិអាមេរិ-កាំងៗ ការដែលមនុស្សមានភេទដូចគ្នា(ប្រុសនិងប្រុស ឬស្រីនិងស្រី)កាន់ដៃគ្នាទៅកន្លែងសាធារណៈ អាមេរិកាំងចាត់ទុកថា មិនគប្បីៗ ថ្វីត្បិតតែអាមេរិកាំងប្រើកាយវិការជាច្រើនក៏ដោយ មានកាយវិការពីរយ៉ាងដែលគេចាត់ទុកថាមិនគប្បីៈ ប្រើម្រាមមួយចង្អុលទៅកាន់អ្នកណាម្នាក់ ផ្ទាត់ដៃដើម្បីហៅអ្នកណាម្នាក់និងសំលឹងមើលអ្នកណាម្នាក់ៗ

គ្រួសារអាមេរិកាំង

ឪពុកម្តាយនិងកូន ជាសមាជិកគ្រួសារអាមេរិកាំង។ សម័យសព្វថ្ងៃ គ្រួសារនីមួយៗមានកូន២ឬ៣នាក់ជាមធ្យម។ នៅពេលដែលកូនអាយុ២១ឆ្នាំ និងកូនរៀបការរួច តាមធម្មតាតែងរស់នៅឆ្ងាយពីឪពុកម្តាយ។ ជួនកាលសមាជិកគ្រួសារជួបគ្នាម្តង ក្នុង១ឆ្នាំ នៅពេលឈប់សំរាក ពេលរៀបអាពាហ៍ពិពាហ៍ បុណ្យខ្មោចជាដើម។ មនុស្សចាស់ជរា ធម្មតារស់នៅឆ្ងាយពីកូនចៅ ជួនកាលឪពុកម្តាយ អាចរស់នៅជាមួយ កូនស្រីឬកូនប្រុស អ្នកខ្លះទៀតរស់នៅផ្ទះ សំរាប់អ្នកចូលនិវត្តន៍ ឬផ្ទះបន្ទប់ពិសេស សំរាប់តែមនុស្សចាស់ ដែលមានអាយុប្រហាក់ប្រហែលគ្នា និងរួមគ្នាធ្វើពិធីផ្សេងៗ ជួនកាល ក្លឹប ព្រះវិហារ និងក្រុមផ្សេងទៀត អាចផ្តល់នូវលទ្ធភាពឲ្យ មនុស្សទាំងនោះ សំរាប់ធ្វើសកម្មភាពផ្សេងៗ



ការកំសាន្ត

អាមេរិកាំងរៀបចំត្រៀមពេលវេលាសំរាប់កំសាន្ត ដូចគ្នានឹងពេលវេលាសំរាប់ធ្វើការដែរ។ គេច្រើនចាត់ទុកថ្ងៃសៅរ៍និងអាទិត្យសំរាប់មើលទូរទស្សន៍ លេងកីឡា ដាំផ្កាឬបន្លែ ជួសជុលផ្ទះ ទៅមើលកុន។ បើសិនជាលោកអ្នកចង់ទៅលេងគេ នៅពេលខាងលើនេះ លោកអ្នកត្រូវទូរស័ព្ទទៅប្រាប់គេជាមុន តើអាចទៅបានឬទេ ។ ក្នុងទីក្រុងនិងជនបទភាគច្រើន មានកន្លែងសំរាប់កំសាន្តជាច្រើន ដែលគេតែងនាំគ្រួសារទៅលំហែកាយ។

រដ្ឋាភិបាលអាមេរិកាំង

រដ្ឋធម្មនុញ្ញអាមេរិកាំង ផ្តល់នូវសិទ្ធិនិងសេរីភាពយ៉ាងទូលំទូលាយៗ រដ្ឋាភិបាល ដែលបានតែងតាំងឡើងដើម្បីការពារសិទ្ធិទាំងនេះ ជារដ្ឋាភិបាលស្មុគស្មាញខ្លាំងណាស់ៗ របបគ្រប់គ្រងរដ្ឋាភិបាល មិនមែនដូចយើងធ្លាប់ដឹងទេ មិនមែនសុទ្ធតែជ្រើសតាំងឡើយ និងរដ្ឋាភិបាលគ្រប់ផ្នែក មិនមែននៅក្រោមការត្រួតត្រារដ្ឋាភិបាលកណ្តាល រដ្ឋបាលជាន់ខ្ពស់ ទេឡើយៗ ជាទូទៅ រដ្ឋាភិបាលអាមេរិកាំងមាន ៣ថ្នាក់គឺ: រដ្ឋាភិបាលជនបទ រដ្ឋាភិបាលរដ្ឋ និងរដ្ឋាភិបាលសហព័ន្ធៗ ថ្នាក់នីមួយៗ មានមុខការជាក់លាក់មួយ និងជារដ្ឋាភិបាល ដែលប្រជារាស្ត្របានបោះឆ្នោតជ្រើសរើសឱ្យធ្វើការមួយអាណត្តិ(កម្រិតឆ្នាំ)ៗ ប្រជារាស្ត្រមិនដែលជាប់ទោស ហើយអាយុលើស១៨ឆ្នាំ អាចបោះឆ្នោតបានៗ

រដ្ឋាភិបាលជនបទ

ជាទូទៅ រដ្ឋាភិបាលនៅជនបទ ចាត់ចែងកិច្ចការប្រចាំថ្ងៃ ដូចជា ដឹកសំរាមយកទៅចោល ផ្តល់ទឹកប្រើប្រាស់ បង្ហូរទឹកកខ្វក់ រក្សាសន្តិសុខ(ភ្នាក់ងារប៉ូលិស ក្រសួងពន្លត់ភ្លើង) និងបណ្ណាល័យៗ ទីក្រុងតូចៗភាគច្រើន មានរដ្ឋាភិបាលផ្ទាល់ ដែលដឹកនាំដោយអភិបាលក្រុង ហៅថា "ម៉ែយ័រ" (Mayor)ៗ បន្ថែមពីលើនេះ មានរដ្ឋាភិបាលសំរាប់ស្រុក(County) ដែលកាន់កាប់ផ្នែកខាងច្បាប់ ដូចជា ចុះបញ្ជីអ្នកបោះឆ្នោត និងចេញសំបុត្រអាពាហ៍ពិពាហ៍ៗ

រដ្ឋាភិបាលរដ្ឋ

ចំនួនរដ្ឋរបស់សហរដ្ឋអាមេរិកទាំងមូល មាន៥០រដ្ឋ។ រដ្ឋនីមួយៗមានអភិបាលរដ្ឋម្នាក់ ហៅថា(Governor) ដែលប្រជារាស្ត្រជាអ្នកបោះឆ្នោតជ្រើសតាំង មានក្រុមនីតិបញ្ញត្តិមួយសំរាប់តែងច្បាប់ និងមានក្រសួងច្រើនក្រសួង។ រដ្ឋាភិបាលរដ្ឋ ដាក់កំរិតអាករថ្លៃលក់(Sales tax) និងអាករផ្សេងៗ(Tax) និងចាត់ចែងកិច្ចការផ្សេងៗ ដែលមានសារៈសំខាន់ សំរាប់ប្រជារាស្ត្រនៅក្នុងរដ្ឋ ដូចជា ការថែទាំផ្លូវ ចេញច្បាប់អនុញ្ញាតិបើកបរ ត្រួតពិនិត្យខាងសុខាភិបាលនិងសន្តិសុខនៅភោជនីយដ្ឋាន និង ក្នុងអាគារជំនួញផ្សេងៗ។

រដ្ឋាភិបាលសហព័ន្ធ

រដ្ឋាភិបាលសហព័ន្ធ តាំងនៅរដ្ឋធានីវ៉ាស៊ីនតោន ឌី ស៊ី ហើយចែកជា៣ផ្នែក : ផ្នែកប្រតិបត្តិ រដ្ឋាភិបាល ផ្នែកតុលាការ និង សភា។ ផ្នែកប្រតិបត្តិមាន លោកប្រធានាធិបតី ទីប្រឹក្សា និងជំនួយៗ មុខការរបស់លោកគឺ អនុវត្តន៍ច្បាប់ ឬ បទបញ្ញារបស់រដ្ឋធម្មនុញ្ញ និងអនុវត្តន៍បញ្ញត្តិរបស់សភា។ ផ្នែកតុលាការ មាន តុលាការជាន់ខ្ពស់ ដែលមានសមាជិក៩នាក់ សុទ្ធតែតែងតាំងដោយលោកប្រធានាធិបតី។ ផ្នែកតុលាការនេះជាក្រសួងមានសមត្ថកិច្ចខ្ពស់បំផុត នៅក្នុងសហរដ្ឋ។ ឯផ្នែកសភា ជាក្រុមតុបតែងច្បាប់ ចែកចេញជា២ផ្នែក : គឺផ្នែកខាងសភាតំណាងរាស្ត្រ ឬរដ្ឋសភា (House) និង ព្រឹទ្ធសភា (Senate)។

បញ្ជីអត្ថបទ

ការធ្វើដំណើរនិងរបៀបនិយាយទាក់ទងឆ្លើយឆ្លងគ្នា
ការធ្វើដំណើរទៅទីផ្សេងៗ..............១៨
ការធ្វើដំណើរដោយជើង..............១៩
ការធ្វើដំណើរដោយកង់..............២០
ការធ្វើដំណើរតាមប៊ីស..............២១
ការធ្វើដំណើរដោយរថយន្តឬម៉ូតូ..........២២
ការធ្វើដំណើរតាមរថយន្តតាក់ស៊ី..........២៣
ការធ្វើដំណើរតាមស៊ីបរ៉ែនិងរថភ្លើង.......២៣
ការធ្វើដំណើរផ្លូវឆ្ងាយ
ការធ្វើដំណើរដោយរថយន្ត..............២៤
ការធ្វើដំណើរតាមប៊ីស..............២៥
ការធ្វើដំណើរតាមរថភ្លើង..............២៦
ការធ្វើដំណើរតាមយន្តហោះ..............២៧
ការការពារនិញ្ញាសុខទៅក្រៅផ្ទះ.....២៨-២៩

របៀបនិយាយទាក់ទងឆ្លើយឆ្លងគ្នា
ការទាក់ទងតាមសំបុត្រ..............៣០
ការផ្ញើរសំបុត្រ..............៣១
ការទទួលសំបុត្រ..............៣១
ការទាក់ទងតាមទូរស័ព្ទ..............៣២
សៀវភៅទូរស័ព្ទ..............៣២
របៀបប្រើទូរស័ព្ទ..............៣២
ទូរស័ព្ទផ្ទាល់ខ្លួន..............៣៣
ទូរស័ព្ទទាក់ទងទៅស្រុកឆ្ងាយ.........៣៣
ថ្លៃឈ្នួលទូរស័ព្ទ..............៣៤
ទូរស័ព្ទសំរាប់សាធារណជនប្រើ........៣៥
ទូរស័ព្ទប្រើតបង់ថ្លៃ ហៅទៅឆ្ងាយ
ឬ ផ្លូវព្រិលមិនបី..............៣៥
តេលេក្រាម....................

រឿងរបស់អ្នកស្រី "សយ"

ច្រើនអាទិត្យក្រោយពីអ្នកស្រី "សយ" មកដល់សហរដ្ឋ គាត់បានទទួលសំបុត្រពីមិត្តម្នាក់ ដែលគាត់ធ្លាប់ស្គាល់នៅស្រុកខ្មែរ។ មិត្តគាត់ប្រាប់ថា គាត់និងកូន ទើបនឹងបានមកដល់សហរដ្ឋ។ អ្នកស្រី "សយ" ឃើញអស័យផ្លួនមិត្តគាត់ ហើយដឹងថា មិត្តគាត់នៅទីក្រុងជាមួយគ្នា តែនៅម្ខាងទៀត។

ព្រឹកមួយ ប្តីគាត់សុខចិត្តនាំអ្នកស្រី "សយ" បង្ហាញឱ្យជិះបឺស ទៅលេងផ្ទះមិត្តគាត់។ គាត់មានការរំភើបអបអរ និងបានជួបមិត្តគាត់ណាស់ គាត់ក៏បានទៀងជិះបឺស ដែលមកឈប់នៅកន្លែងបឺសឈប់ ដែលគាត់រង់ចាំ។ គាត់បានបង់ថ្លៃបឺស (ដោយទំលាក់កាក់ ទៅក្នុងប្រអប់ ពេលគាត់ទៀង) ហើយទៅរកកន្លែងអង្គុយ។

ក្រោយពីជិះឡានបន្តិចមក អ្នកស្រី "សយ" ភ័យរសាប់រសល់ ដោយគាត់មិនដឹងទៅដល់កន្លែងណា។ គាត់ក៏ទៅសួរអ្នកអង្គុយជិត ហើយបង្ហាញអាស័យដ្ឋានរបស់មិត្តគាត់ អ្នកនោះក៏ប្រាប់ថា គាត់ជិះប៊ីសខុស។ អ្នកស្រី "សយ" ក៏ចុះនៅចំណតខាងមុខ ហើយភ័យដោយមិនដឹងធ្វើម៉េចទៀត។ ភ្នាក់ងារប៉ូលិសម្នាក់នៅជិតនោះ ឃើញដូច្នេះ ក៏ដើរចូលមកជិត អ្នកស្រីក៏បង្ហាញអាស័យដ្ឋានរបស់មិត្តគាត់។ ប៉ូលិសមើលញញឹមៗ ហើយនិយាយថា មិននៅឆ្ងាយពីទីនេះទេ។ ប៉ូលិសនាំគាត់ទៅហាងលក់ទំនិញមួយនៅជិតនោះ ហើយទូរស័ព្ទហៅឡានតាក់ស៊ី។ ពេលឡានតាក់ស៊ីមកដល់ ប៉ូលិសក៏ហុចអាស័យដ្ឋានឲ្យ។

មួយសន្ទុះក្រោយមក ក៏មកដល់ផ្ទះមិត្តគាត់។ អ្នកស្រី "សយ" ហុច ២ដុល្លារឲ្យអ្នកបើកតាក់ស៊ី រួចក៏ចុះពីឡាន។ ពេលគាត់គោះទ្វារផ្ទះមិត្តគាត់ មិត្តគាត់ក៏ឆ្លើយ ហើយបើកទ្វារ។ អ្នកស្រី "សយ" បានធូរស្រួល ហើយសប្បាយនឹងជួបមិត្តគាត់ណាស់។ នៅពេលដែលអ្នកស្រី "សយ" ត្រលប់ទៅផ្ទះវិញ គាត់ទូរស័ព្ទទៅឡានប៊ីស សួរពីកន្លែងឡានប៊ីសឈប់ ដែលមាននៅជិតផ្ទះមិត្តគាត់ និងឡានប៊ីស ដែលដឹកយកទៅដល់ផ្ទះគាត់។

ការធ្វើដំណើរទៅទីជិតៗ

ប្រជាជនអាមេរិកាំង ធ្វើដំណើរដោយជើង ជិះកង់ ជិះឡាន ជិះប៊ីស និង ជួនកាលជិះរទេះភ្លើងក្នុងដីៗ មុនដំបូង យើងគួរដឹងឲ្យប្រាកដ តើយើងចង់ទៅណា ហើយមានចម្ងាយប៉ុន្មាន បន្ទាប់មក យើងអាចជ្រើសរើសយានជំនិះ ដែលយើងត្រូវធ្វើដំណើរៗ

យើងគួរយកអត្តសញ្ញាណប័ណ្ណ (ក្រដាសសំរាប់សំគាល់ខ្លួន) និងលេខទូរស័ព្ទរបស់អ្នកអាណាព្យាបាល ឬ មិត្តសំរាប់ដល់ពេលវង្វេង ឬ ពេលមានអាសន្នៗ



ការធ្វើដំណើរដោយថ្មើរជើង

ការដើរជារបៀបមួយ យ៉ាងប្រសើរ ដែលអាចនាំយើងឆាប់កាត់ផ្លូវ និង ជាការហាត់ប្រាណផង។ មានការណ៍ខ្លះដែលយើងគួរដឹង មុននឹងចេញដើរទៅក្រៅ :

- ដឹងជាមុនពីធាតុអាកាស ខោអាវត្រូវជាក់ចុះល្អ ដើម្បីយើងអាចស្លៀកពាក់ ឲ្យស្របតាមធាតុអាកាស។
- យើងគួរដើរខាងឆ្វេងដៃ ដើម្បីកុំឲ្យមានគ្រោះថ្នាក់។
- ដឹងចម្ងាយជាមុន។

យើងគួររៀនមើលសញ្ញាទាំងនេះ មុននឹងឆ្លងផ្លូវ :

- WALK ជាសញ្ញាឲ្យឆ្លងផ្លូវ
- DON'T WALK ជាសញ្ញាកុំឆ្លងផ្លូវ
- មុននឹងឆ្លងផ្លូវ យើងត្រូវមើលឆ្វេងស្ដាំ ក្រែងលោមានឡានបើកមក។ នៅទីក្រុងខ្លះ បើលោកអ្នកឆ្លងផ្លូវមិនបានត្រឹមត្រូវ ប៉ូលិសនឹងចាប់ពិន័យ។ ឧ. ឆ្លងផ្លូវមិនចំកន្លែង ផ្លូវដែលមានសញ្ញាភ្លើងឈប់។
- កុំទទួលជិះឡាន បើអ្នកមិនស្គាល់ហៅឲ្យជិះ។
- កុំដើរម្នាក់ឯងនៅពេលយប់។

29

ការធ្វើដំណើរដោយកង់

ប្រជាជនអាមេរិកាំងភាគច្រើន ជិះកង់ដើម្បីកំសាន្ត និង ជាការហាត់ប្រាណផង។ អ្នកខ្លះ ជិះកង់ទៅសាលា ឬ ទៅធ្វើការ។ ច្បាប់ចំណាប់ជិះកង់ទៅសាលា ក៏មានសារៈសំខាន់ដូចដើរ ឬ ជិះឡានដែរ នៅកន្លែងខ្លះ មានផ្លូវសំរាប់តែជិះកង់ ហើយនិងមានភ្លើងសញ្ញាស្តុបកង់ បង្ហាញ។

- យើងត្រូវជិះនៅខាងស្តាំដៃរាល់ពេល។
- ពេលបត់ត្រូវលើកដៃ។
- កង់មួយជិះតែម្នាក់បានហើយ អាចថែមកៅអីសំរាប់កូនក្មេង។
  បើជិះនៅពេលយប់ គួរប្រើ :
- ចង្កៀងនៅកង់។
- ពេលចតកង់ទុក ត្រូវចាក់សោរអោយមាំទាំ។

លើកដៃធ្វើសញ្ញាមុននឹងបត់

ការធ្វើដំណើរតាមប៊ីស

ការធ្វើដំណើរតាមប៊ីស ជាមធ្យោបាយសាមញ្ញបំផុត ក្នុងការប្រើយានជំនិះសាធារណៈ។

នៅពេលយើងជិះប៊ីស យើងត្រូវដឹង កន្លែងណាត្រូវទៅឡើងជិះនិងត្រូវចុះ។ តាមធម្មតា ប៊ីសតែងមានលេខនិងឈ្មោះកន្លែង ដែលប្រាប់ផ្លូវរត់កាត់ និងកន្លែងទៅឈប់។ មុននឹងជិះ យើងគួររកអ្នកណាម្នាក់ ឱ្យជួយសុំប័ណ្ណ ប្រាប់ម៉ោងឡានប៊ីសចេញដំណើរ និង ដល់ទីដៅ។ ឡានប៊ីសមកឈប់ នៅកន្លែងដែលមានសញ្ញាប៊ីសឈប់ (Bus stop) មួយដែលតាមកំណត់ពេលម៉ោងណាមួយ ដូច្នេះយើងត្រូវមកចាំ ឱ្យបានទាន់ពេលម៉ោង និងត្រូវពេល។

របៀបជិះប៊ីស

- នៅកន្លែងឈប់ចាំជិះប៊ីស យើងត្រូវឈរចាំតាមលេខរៀង។
- នៅទីក្រុងខ្លះ យើងត្រូវបង់លុយថ្លៃប៊ីសឱ្យគ្រប់ចំនួនជាស្រេច។ ឧ. ថ្លៃប៊ីស៥០សេនឬ៦០សេន យើងត្រូវមាន៥០សេនឬ៦០សេន ទុកជាស្រេច។

ពេលចុះចេញពីប៊ីស

យើងត្រូវសង្កេតមើល តើប៊ីសទៅដល់ណា យើងត្រូវទាញខ្សែកណ្ដឹងឬចុចកណ្ដឹង មុនដល់កន្លែងដែលយើងចង់ឈប់បន្តិច។

តាមធម្មតា ទ្វារនៅខាងក្រោយ ច្រើនមានភ្លើងរឹបតង។ បើភ្លើងឆេះឡើង ទើបយើងអាចចុះចេញបាន។
- ពេលឡើងចូលភ្លាម យើងគួរដឹងថា កៅអីនៅខាងមុខ ២ឬ៣ ទុកសំរាប់អ្នកពិការឬមនុស្សចាស់។ យើងគួរទៅរកកន្លែងផ្សេងទៀត។
- ភាគច្រើន នៅក្នុងប៊ីស គេហាមមិនឱ្យជក់បារី ទទួលទានទឹក អាហារ បើកវិទ្យុនិងពង្រាយឬចោលសំរាម។
- ថ្ងៃសៅរ៍និងអាទិត្យ ពេលម៉ោងប៊ីសធ្វើដំណើរមានផ្លាស់ប្ដូរ។
- នៅតំបន់ឆ្ងាយៗឡានប៊ីសមិនសូវឈប់ទេ។
- មុននឹងយើងជិះឡានប៊ីស យើងគួរសួរអ្នកអាណាព្យាបាល ឬមិត្ត ឱ្យពន្យល់ពីផ្លូវប៊ីស និង តម្លៃជិះសិន។

ការធ្វើដំណើរដោយរថយន្តឬម៉ូតូ

ដោយនៅតំបន់ដាច់ស្រយាលពីទីក្រុង មិនសូវមានយានជំនិះសាធារណៈ ដូចជាប៊ីស្សរថភ្លើង គេចូលចិត្តជិះឡានៗ ប៉ុន្តែយើងត្រូវដឹងថា មានឡាន នាំឲ្យមានចំណាយច្រើន ដូចជា ថ្លៃប្រេងសាំង ប្រេងម៉ាស៊ីន ជួសជុល បង់ប្រាក់ធានា ជូនកាលបង់ថ្លៃកាត់ទោសផងៗ អ្នកភ្ញៀវខ្លះ ទិញឡានថ្មី ក្រោយមកទើបដឹងថា មិនអាចបង់ថ្លៃកាត់ទោសឬប្រាក់ធានាបានៗ យើងគួរទិញឡានជំនុំវិញៗ

មានការណ៍ខ្លះ ដែលយើងគួរដឹងមុននឹងបើកបរ :

- អ្នកបើកបរទាំងអស់ ត្រូវមានច្បាប់អនុញ្ញាតិបើកបរៗ
- រថយន្តឬជំនិះ ត្រូវយកទៅចុះបញ្ជី ក្នុងរដ្ឋអ្នករស់នៅៗ
- ជាការល្មើសច្បាប់ បើយើងផឹកស្រាហើយបើករថយន្តៗ
- នៅរដ្ឋខ្លះ ត្រូវមានអាយុយ៉ាងតិច១៦ឆ្នាំទើបបើកបានៗ
- នៅរដ្ឋភាគច្រើន យើងត្រូវទៅរៀនបើកសិន ទើបអាចទៅប្រលងយកច្បាប់អនុញ្ញាតិបើកបរបានៗ
- នៅរដ្ឋភាគច្រើន តម្រូវឲ្យម្ចាស់ឡាន ទិញច្បាប់ធានា សំរាប់ចំណាយលើអ្នករបួសពេលមានគ្រោះថ្នាក់

ច្បាប់ទាំងនេះ ខុសគ្នា ពីរដ្ឋមួយទៅរដ្ឋមួយៗ រដ្ឋនីមួយៗតែងមានក្រសួងខាងយានជំនិះ សំរាប់ត្រួតត្រានិងផ្តល់ព័ត៌មានៗ យើងគួរសួរមិត្តយើង ពីច្បាប់នៅក្នុងរដ្ឋដែលយើងរស់នៅៗ

ចំពោះច្បាប់សំរាប់អ្នកជិះម៉ូតូ គឺដូចគ្នានឹងរថយន្តដែរ តែរដ្ឋភាគច្រើន តម្រូវឲ្យអ្នកជិះ ពាក់មួកការពារក្បាល ឬ ច្បាប់អនុញ្ញាតិពិសេសៗ



ការធ្វើដំណើរតាមរថយន្តតាក់ស៊ី

ទីក្រុងធំៗនិងតំបន់ផ្សេងទៀត តែងមានរថយន្តតាក់ស៊ីៗ រថយន្តតាក់ស៊ីយកថ្លៃច្រើន ហើយធម្មតា អ្នកជិះត្រូវបង់កម្រៃក្រៅ (Tip) ។ ភាគច្រើនតម្លៃជិះគិតដោយម៉ាស៊ីន ឬ ទៅតាមតំបន់ដែលគេបានកំរិតតម្លៃ។ ប៉ុន្តែបើយើងធ្វើដំណើរឆ្ងាយ យើងអាចតថ្លៃបាន។

នៅពេលយើងត្រូវធ្វើដំណើរទៅណា ហើយគ្មានអ្វីជិះនោះ យើងអាចទូរស័ព្ទ ហៅរថយន្តតាក់ស៊ីពីផ្ទះ ឬ ពីកន្លែងណាក៏ដោយ នៅគ្រប់ពេល មិនថាយប់ ឬ ថ្ងៃឡើយ។ អ្នកអាចរកលេខទូរស័ព្ទរថយន្តតាក់ស៊ី នៅក្នុងសៀវភៅទូរស័ព្ទពណ៌លឿង ផ្នែកគេសរសេរ Taxi ឬ Cab ។

ការធ្វើដំណើរតាមរថភ្លើងក្រោមដី(Subway) និងតាមរថភ្លើង

នៅក្នុងទីក្រុងធំៗ ខ្លះ មានរថភ្លើងដែលរត់យ៉ាងលឿន នៅក្នុងដី ឬ លើដីហៅថា ស៊ីបវេ(Subway) ។ ដើម្បីទៅជិះស៊ីបវេ យើងត្រូវដឹងកន្លែងដែលវាឈប់ ដឹងរបៀបទិញសំបុត្រ និង ដឹងស៊ីបវេណា ទៅកន្លែងណា។ បើមិនដឹង នៅក្នុងកន្លែងយើងមានស៊ីបវេ យើងគួរសួរអ្នកអាណាព្យាបាល ឬ មិត្ត ឲ្យជួយបង្ហាញពីរបៀបជិះ។

ការធ្វើដំណើរឆ្ងាយរថយន្ត

មុននឹងចេញធ្វើដំណើរ យើងគួររៀបចំជាមុនដូចជា:

- ឆែកមើលប្រេង និងម៉ាស៊ីនក្រងឡូច។
- ត្រូវចេះមើលផែនទីប្រាប់ផ្លូវ និង សញ្ញានៅតាមផ្លូវ ផែនទីមានលក់នៅកន្លែងចាក់ប្រេងនានា។
- កុំបើកបរ ប្រសិនបើអ្នកបានផឹកថ្នាំណាខ្លាំង ឬផឹកស្រា។
- ម្ហូបអាហារ បាយទឹក និងប្រេងសាំង តែងមានជាហូរហែរ នៅតាមផ្លូវ។
- នៅពេលងងុយដេក ត្រូវឈប់នៅលើចិញ្ចើមថ្នល់ ឬ រក កន្លែងសំរាក។
- កុំបោះសំរាម ឬ ស្តោះទឹកមាត់ តាមទ្វារ បង្អួចឡាន បើប៉ូលិសឃើញនឹងពិន័យជាទម្ងន់។
- កុំឲ្យអ្នកដែលមិនស្គាល់ ជិះឡាន។
- ពេលបើកបរ ទ្វាររថយន្ត ត្រូវចាក់សោរឲ្យជាប់។
- កុំបើកលឿនហួសកំរិត ដែលគេបានដាក់សញ្ញាប្រាប់តាមផ្លូវ។
- នៅផ្លូវធំៗខ្លះ មានស្ថានីយចាំទារយកថ្លៃបើកបរ ដូច្នេះយើងតោងបង់ថ្លៃបើកបរផ្លូវគេ។
- ពេលបើកបរត្រូវដាក់ខ្សែក្រវាត់ជាប់ជានិច្ច។

មុនពេលធ្វើដំណើរ យើងត្រូវមើលផែនទីឲ្យដឹងផ្លូវ ចម្ងាយ ខណៈពេលដើម្បីធ្វើដំណើរឲ្យបានស្រួល។



ការធ្វើដំណើរតាមប៊ីស

ការធ្វើដំណើរតាមប៊ីស ជួយឲ្យយើងចំណាយអស់លុយតិចៗ

- យើងត្រូវទៅទិញសំបុត្រ នៅស្ថានីយ៍ ចំណត ។
- បើពិនជា យើងមិនបានទិញទុកជាមុន យើងគួរទៅ ចំណតឲ្យបានមុនម៉ោងៗ
- ប៊ីសចេញទៅតាមម៉ោងកាល់ៗ ដូច្នេះយើងត្រូវដឹង ម៉ោង ដែលប៊ីសចេញដំណើរៗ
- នៅខាងក្រោយប៊ីស មានបន្ទប់សំរាប់បត់ជើងៗ
- ត្រូវមើលការហាមប្រាមនៅក្នុងប៊ីស ដូចជាមិនឲ្យ ជក់បារី មិនឲ្យទទួលទានអាហារ និងបើកវិទ្យុៗ
- យើងអាចទិញម្ហូបអាហារ នៅតាមភោជនីយដ្ឋាន តូចៗ ដែលប៊ីសឈប់ទិញម្ហូបៗ



ទិញសំបុត្រឡានប៊ីស

ការធ្វើដំណើរតាមរថភ្លើង

ការធ្វើដំណើរតាមរថភ្លើង ស្រួលជាងតាមប៊ីស តែរថភ្លើងមិនសូវសំបូរ ហើយអស់លុយច្រើនជាង។

- ធម្មតា យើងត្រូវទិញសំបុត្រ នៅស្ថានីយ៍ ចំណត ។
- យើងត្រូវទៅ ឱ្យបានមុនម៉ោង ព្រោះរថភ្លើងចេញទៀងម៉ោងណាស់។
- បង្គន់មាននៅខាងក្នុងរថភ្លើង។
- នៅក្នុងរថភ្លើង មានភោជនីយដ្ឋាន តែថ្លៃបន្តិច។
- ត្រូវដឹងប្រាកដ ពីលេខទ្វារចូល ទៅទូររថភ្លើងរបស់អ្នក ដែលអ្នកត្រូវធ្វើដំណើរ ព្រោះទូរផ្សេងគ្នា ទៅកន្លែងខុសៗគ្នា។ ដូច្នេះ ត្រូវស្ថិតនៅក្នុងទូរណាដែលគេចាត់ឱ្យ។
- កុំជក់បារីនៅក្នុងទូររថភ្លើងណា ដែលសំរាប់អ្នកឥតជក់បារី។ សូមសម្លឹងរកមើលសញ្ញា ហាមជក់ ឬ ក៏សួរអ្នកបើកបរ។
- កុំអើតក្បាលចេញក្រៅ ឬ ដាក់ដៃចេញក្រៅ។
- ការធ្វើដំណើរតាមរថភ្លើងទាំងស្រួល អស់លុយតិចជាងតាមយន្តហោះ។
- បើយើងមិនចង់ដេកនៅលើកៅអី យើងអាចទិញយកបន្ទប់សំរាប់ដេក តែថ្លៃជាងសំបុត្រធម្មតា។

អ្នកធ្វើការនៅរថភ្លើង ឆែកសំបុត្រ

-២៦-

ការធ្វើដំណើរតាមយន្តហោះ

តាមធម្មតា ការធ្វើដំណើរតាមយន្តហោះអស់លុយច្រើន។

- យើងអាចទិញសំបុត្រទុកជាមុន។ ភ្នាក់ងារធ្វើដំណើរ (Travel Agency) អាចឱ្យពត៌មានដល់យើង។
- អ្នកធ្វើដំណើរទាំងអស់ ត្រូវទៅប្រាប់អ្នកឆែកសំបុត្រ ៤៥នាទី មុនពេលយន្តហោះចេញដំណើរ។ ក្រុមហ៊ុនអាកាសចរណ៍ មានច្បាប់កំរិតអំពីទម្ងន់របស់ និងវត្ថុដែលយើងអាចយកបាន។
- យើងគួរដឹងពីទម្ងន់របស់ ដែលក្រុមហ៊ុនអាកាសចរណ៍អនុញ្ញាតិឱ្យយក ជួនកាលវ៉ាលីសពីរ កាបូបយួរមួយក្នុងម្នាក់ៗ។

រដ្ឋការនឹងឆែកឆេររកអាវុធ ឬ គ្រឿងដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ មុននឹងអនុញ្ញាតិឱ្យយើងចូលក្នុងយន្តហោះ។

បើចង់ធ្វើដំណើរតាមយន្តហោះ យើងគួរសួរពីរបៀបជិះ ពីអ្នកអាណាព្យាបាល ឬ មិត្តជាមុនសិន។

នៅចំណតអាកាសយាន

-កុំដើរនៅទីងងឹត ដែលអ្នកឯទៀតមិនអាចមើល ឃោកអ្នកឃើញៗ

-ចូរប្រយ័ត្នទីកន្លែងស្ងាត់ គ្មានមនុស្សៗ មានគេ មានឯងនៅជិត អាចធ្វើឲ្យមនុស្សមិនហ៊ានធ្វើ ផ្តេសផ្តាសៗ

-ចៀសវាង កុំដើរម្នាក់ឯងនៅពេលយប់ៗ

-ពេលយប់ កុំឲ្យកូនក្មេងចេញក្រៅៗ វាអាចនាំឲ្យមានគ្រោះថ្នាក់ បើបណ្ដោយឲ្យវា នៅម្នាក់ឯង ពេលយប់ងងឹតៗ

-ជាចំណាប់ខ្លួនទៅ ត្រូវប្រយ័ត្នមនុស្សចម្លែកៗ ជាការសំខាន់ និងប្រាប់កូន កុំឲ្យជិះរថយន្ត ម៉ូតូ កង់ ឬ ទទួលអំណោយពីមនុស្សដែលវាមិនស្គាល់ៗ ស្រីៗត្រូវប្រយ័ត្ន ជាពិសេសចំពោះមនុស្សប្រុស ដែលមិនស្គាល់ ព្រោះការចាប់រំលោភអាច កើតឡើងៗ

-ការទុកប្រាក់ច្រើនរបស់មានតម្លៃ ដូចជា មាសពេជ្រ នៅជាប់នឹងខ្លួននាំឲ្យមានគ្រោះថ្នាក់។ បើមិនអាចចៀសវាបានទេ ពេលទុកក្នុងហោប៉ៅ ឬ កាបូប ត្រូវកុំឲ្យគេងាយមើលឃើញ។

ពេលមានការអាសន្នកើតឡើង ឬលង់រ័យនរណាម្នាក់ កុំញញើតនឹងហៅរកឬទូរស័ព្ទទៅភ្នាក់ងារប៉ូលិសឲ្យឆាប់។ ការហៅរកប៉ូលិស ទោះបីគ្មានការអ្វីក៏ដោយ ក៏ជាការប្រសើរជាជាងទុកឲ្យមានគ្រោះថ្នាក់កើតឡើងដល់រូបកាយដែរ។ លោកអ្នកមានសិទ្ធិ និងបានទទួលការការពារនិងជំនួយគ្រប់បែបយ៉ាង ដែលមានសំរាប់ជនជាតិអាមេរិកាំង។

បើសិនជាលោកអ្នកទទួលរងគ្រោះ ពីបទឧក្រិដ្ឋណាមួយ ចូរទូរស័ព្ទទៅភ្នាក់ងារប៉ូលិសភ្លាម។ នៅតំបន់ភាគច្រើន លោកអ្នកអាចបង្វិលលេខភាពអាសន្នគឺ ៩១១ (911) ទៅរកប៉ូលិស ឬ ក៏បង្វិលលេខ "0" ទៅអូប៉េរ៉ាទ័រ (Operator) ហើយសុំឲ្យគេជួយ។

ការទាក់ទងតាមសំបុត្រ

ពេលណាលោកអ្នកចង់ផ្ញើរសំបុត្រ សូមលោកអ្នកការខ្ចងសំបុត្រ ជាភាសាអង់គ្លេសឲ្យបានច្បាស់ និង សរសេរឈ្មោះ អស័យដ្ឋានឲ្យបានត្រឹមត្រូវ។ ខាងស្តាំនេះជាឧទាហរណ៍។



ការផ្ញើរសំបុត្រ

- ដើម្បីផ្ញើរសំបុត្រ យើងត្រូវបិទតែមប្រិ តម្លៃ១៥សេន បើផ្ញើរទៅក្នុងសហរដ្ឋនិងកាណាដា និងតម្លៃ៣១សេនបើផ្ញើរទៅក្រៅប្រទេស។
- យើងអាចទិញតែមប្រិទៅប៉ុស្តិ៍។
- យើងអាចផ្ញើរសំបុត្រ ដោយយកសំបុត្រទៅទំលាក់ក្នុងប្រអប់សំបុត្រ ដែលមានពណ៌ខៀវនិងក្រហម នៅតាមចិញ្ចើមថ្នល់ និង នៅប៉ុស្តិ៍។
- ធម្មតា ប៉ុស្តិ៍បិទទ្វារនៅថ្ងៃអាទិត្យ និង ថ្ងៃបុណ្យ។
- នៅស្រុកស្រែ ប្រអប់សំបុត្រនៅមុខផ្ទះ គេដាក់ទង់ដែកពណ៌ក្រហមជាសញ្ញាប្រាប់ថា មានសំបុត្រត្រូវផ្ញើរ។
- កញ្ចប់និងខ្សែអាត់ គួរយកទៅផ្ញើរនៅប៉ុស្តិ៍។



ប្រអប់សំបុត្រនៅផ្ទះ

ដាក់សំបុត្រនៅកន្លែងនេះ

ការទទួលសំបុត្រ

គេយកសំបុត្រមកចែក រាល់ថ្ងៃនៅផ្ទះ លើកលែងតែថ្ងៃអាទិត្យនិងថ្ងៃបុណ្យ។ ផ្ទះបន្ទប់នីមួយៗមានប្រអប់សំបុត្រមួយ ដែលធម្មតានៅជិតផ្លូវចូលអាគារ។ អ្នកខ្លះអាចជួលប្រអប់នៅប៉ុស្តិ៍ សំរាប់ទទួលសំបុត្រ។

ការកត់សំគាល់

បើសិនជាយើងបានទទួលសំបុត្ររបស់អ្នកដទៃផ្សេងទៀត សូមកុំបើកសំបុត្រនោះ។ យើងគួរផ្ញើរត្រលប់ទៅវិញ ហើយគួរសួរអ្នកអាណាព្យាបាល ឬ មិត្តភ័ក្តិជួយពន្យល់ប្រាប់។

ការទាក់ទងតាមទូរស័ព្ទ

ទូរស័ព្ទជាមធ្យោបាយមួយមានប្រយោជន៍ ក្នុងការទាក់ទងគ្នា ហើយដែលគេចូលចិត្តប្រើ។ មានកន្លែងជាច្រើន មានទូរស័ព្ទសំរាប់សាធារណជនប្រើ ដូចជា នៅតាមការិយាល័យ ហាងទំនិញៗល។ ផ្ទះសឹងតែទាំងអស់ សុទ្ធតែមានទូរស័ព្ទ។

សៀវភៅទូរស័ព្ទ

សៀវភៅទូរស័ព្ទមានពីរយ៉ាង :

- សៀវភៅក្រដាសស មានចុះលេខទូរស័ព្ទ របស់អ្នកដែលមានទូរស័ព្ទ ហើយមានចុះនាមត្រកូល តាមអក្សររៀង។
- សៀវភៅក្រដាសលឿង មានចុះលេខទូរស័ព្ទ របស់ក្រុមហ៊ុនជំនួញនិងមុខរបរផ្សេងៗ។ ឧទាហរណ៍ បើយើងត្រូវការឡានតាក់ស៊ី សូមបើកមើលលេខទូរស័ព្ទ ក្នុងផ្នែកដែលមានសរសេរ Taxi

របៀបប្រើទូរស័ព្ទ

យើងម្នាក់ៗមានលេខទូរស័ព្ទផ្សេងគ្នា។ លេខទូរស័ព្ទនីមួយៗមាន ១០ខ្ទង់ចែកចេញជា លេខអឺរ៉ាកូដ(Area code) មាន៣ខ្ទង់ និង ៧ខ្ទង់ទៀត។ ឧទាហរណ៍ លោក ឯក បូ មានលេខទូរស័ព្ទ ៧០៣-៥២៥-១២១៣។ ៧០៣ជាលេខអឺរ៉ាកូដ។ បើយើងប្រើទូរស័ព្ទឆ្លើយឆ្លងគ្នាជិតៗ យើងប្រើតែ៧ខ្ទង់ ចុងក្រោយទេ គឺលេខ ៥២៥-១២១៣។ បើទាក់ទងទៅរដ្ឋផ្សេង ឆ្ងាយៗ ត្រូវប្រើទាំង១០ខ្ទង់គឺលេខ ៧០៣-៥២៥-១២១៣ ។

ទូរស័ព្ទផ្ទាល់ខ្លួន

បើចង់ភ្ជាប់ទូរស័ព្ទប្រើផ្ទាល់ខ្លួន ត្រូវទាក់ទងក្រុមហ៊ុនទូរស័ព្ទ។

- ប្រភេទប្រើ : នៅពេលដែលយើងទៅសុំគេឲ្យដាក់ទូរស័ព្ទ គេនឹងតម្រូវឲ្យយកប្រាក់ចំនួន ៤០.០០ដុល្លារ។

១-ប្រភេទកំរិតចំនួនប្រើ: គេអនុញ្ញាតិឲ្យយើងប្រើតាមចំនួនដែលគេកំរិតក្នុងមួយខែ ដោយឲ្យយើងបង់ថ្លៃប្រាក់មួយចំនួន បើយើងប្រើលើស យើងត្រូវបង់ប្រាក់បន្ថែម។

២-ប្រភេទឥតកំរិត: យើងអាចប្រើតាមចិត្ត តែថ្លៃជាងប្រភេទទី១។

៣-ទូរស័ព្ទប្រើរួមគ្នា : ផ្ទះពីរឬបី ប្រើលេខទូរស័ព្ទតែមួយរួមគ្នា តែមានទូរស័ព្ទនៅតាមផ្ទះរៀងខ្លួន។

ប្រើទូរស័ព្ទទាក់ទងទៅស្រុកឆ្ងាយ

បើសិនជាលោកអ្នកចង់ប្រើទូរស័ព្ទ ហៅទៅម្នាក់ទៀត ដែលនៅខេត្តផ្សេង ឆ្ងាយពីគ្នា លោកអ្នកត្រូវប្រើឬបង្វិលលេខទាំង១០ខ្ទង់ ដែលគេហៅថា ចំងាយឆ្ងាយ(Long distance call)។

ក្រុមហ៊ុនទូរស័ព្ទ ឲ្យលោកអ្នកបង់ប្រចាំខែតែនៅពេលដែលលោកអ្នកហៅទាក់ទងគ្នាជិតៗប៉ុណ្ណោះ បង្វិល៧ខ្ទង់ ។ តែបើលោកអ្នកទាក់ទងគ្នា ទៅឆ្ងាយៗ ខេត្តផ្សេងៗ លោកអ្នកនឹងត្រូវបង់ប្រាក់បន្ថែម។ លោកអ្នកត្រូវបង់ប្រាក់តាមពេលវេលា គឺគេរាប់នាទី។ បើយើងនិយាយយូរ យើងនឹងត្រូវបង់ប្រាក់រឹតតែច្រើន ដែលគេគិតបញ្ចូលទៅក្នុងថ្លៃឈ្នួលប្រចាំខែ។

ការប្រើទូរស័ព្ទទាក់ទងទៅឆ្ងាយ មានពីរប្រភេទ : ទី១ គឺយើងទាក់ទងគ្នាផ្ទាល់ ដោយខ្លួនឯង។ ទី២ ដោយហៅឲ្យអ្នកធ្វើការៈអ្នកបំរើទូរ(Operator) ជួយបង្វិលលេខហៅឲ្យ។

១-ប្រភេទទី១ : ទាក់ទងគ្នាផ្ទាល់: គឺយើងបង្វិលលេខទូរស័ព្ទ ១០ខ្ទង់ និយាយគ្នាផ្ទាល់ ដោយមិនបាច់រកអ្នកបំរើទូរជួយ។

ហេតុការណ៍ខ្លះ: ពីការទាក់ទងគ្នាផ្ទាល់តាមទូរស័ព្ទ:

តម្លៃប្រើទូរស័ព្ទទាក់ទងគ្នាទៅឆ្ងាយ ផ្លាស់ប្តូរទៅតាមពេលវេលា :

ក-ចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពីម៉ោង១១យប់ ទល់ម៉ោង៨ព្រឹក និងចាប់ពីម៉ោង១១យប់ថ្ងៃសុក្រ ទល់ថ្ងៃអាទិត្យម៉ោង៥ល្ងាច តម្លៃចុះថោកប្រហែល ៦០% ។

ខ-ចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ និងថ្ងៃបុណ្យ ចាប់ពីម៉ោង៥ល្ងាចទល់ម៉ោង១១យប់ តម្លៃចុះប្រហែល ៣៥% ។

គ-ពេលថ្លៃជាងគេ ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពីម៉ោង៨ព្រឹកដល់ម៉ោង៥ល្ងាច។

-មុននឹងប្រើទូរស័ព្ទ និយាយទៅខេត្តឆ្ងាយ ប្រើ១០ខ្ទង់ យើងគួរសួរអ្នកអាណាព្យាបាលឬមិត្តជាមុនសិន។

-យើងត្រូវដឹងពីការខុសម៉ោងគ្នា នៅសហរដ្ឋអាមេរិក។

ចាប់ពីរដ្ឋដែលនៅតាមឆ្នេរសមុទ្រខាងកើត ទៅទល់នឹងរដ្ឋដែលនៅតាមឆ្នេរសមុទ្រខាងលិច មានចំនួនខុសគ្នា ៣ម៉ោង។ ឧទាហរណ៍ រដ្ឋកាលីហ្វ័រញ៉ា ខុសគ្នា៣ម៉ោងក្រោយញូវយ៉ក: គឺម៉ោង៥ល្ងាចនៅកាលីហ្វ័រញ៉ា ត្រូវនឹងម៉ោង៨ល្ងាចនៅញូវយ៉ក។

-និយាយទាក់ទងគ្នាឆ្ងាយ អស់ប្រាក់ច្រើនជាងនិយាយជិតៗ។

២-ប្រភេទទី២: ការប្រើទូរស័ព្ទ ដោយហៅអូប៉េរ៉ាទ័រ និយាយហៅអ្នកម្នាក់ទៀត : យើងត្រូវបង្វិលលេខ "០" ហៅ អូប៉េរ៉ាទ័រ និយាយ ហើយនិយាយប្រាប់អូប៉េរ៉ាទ័រ ថា កូឡិចខល(Collect call) ឬប្រាប់ឈ្មោះអ្នកណាម្នាក់ដែលលោកអ្នកចង់និយាយផ្ទាល់ ភើសិនធូភើសិន (Person to person) ។

-កូឡិចខល(Collect call) : គឺការទាក់ទងគ្នាឆ្ងាយ ហើយដែលសុំឱ្យអ្នកម្ខាងទៀតបង់ថ្លៃ។

-ភើសិនធូភើសិន(Person to person) : គឺការទាក់ទងគ្នាឆ្ងាយ តែយើងសុំនិយាយ ចំពោះតែអ្នកណាម្នាក់ដែលយើងចង់និយាយផ្ទាល់។

៣-ថ្លៃឈ្នួលទូរស័ព្ទ : យើងត្រូវបង់ប្រាក់ រៀងរាល់ខែ។ បើយឺតយ៉ូរ ក្រុមហ៊ុនទូរស័ព្ទ អាចផ្តាច់ទូរស័ព្ទ ឈប់ឱ្យយើងប្រើ។

ទូរស័ព្ទសំរាប់សាធារណជនប្រើ

ទូរស័ព្ទរបៀបនេះ ប្រើនមាននៅតាមកន្លែងចាក់ប្រេងសាំង ភោជនីយដ្ឋាន ទីប្រជុំហាងទំនិញ នៅតាមផ្លូវវែង ចំណតរថភ្លើង និង ឡានប៊ីស។

-ត្រូវដាក់កាក់តាមរន្ធកាក់ៗ តម្លៃហៅមួយៗមាន : ១០សេន ១៥សេន ២០សេន ២៥សេន។

-បើហៅទៅឆ្ងាយ ត្រូវការកាក់ច្រើនៗ យើងត្រូវរក អ្នកបំរាំទីរន្ធិយដ្ឋាន ហើយគេនឹងប្រាប់យើងថាត្រូវដាក់កាក់ប៉ុន្មាន។

-បើសិនជាអ្នកម្ខាងទៀត ឥតនៅផ្ទះ ឬ ទូរស័ព្ទគេជាប់រវល់ ពេលយើងដាក់ចុះ កាក់នឹងធ្លាក់ចុះមកក្រោម ដែលយើងអាចយកមកវិញបាន។

ទូរស័ព្ទដែលប្រើឥតបង់ថ្លៃ ដែលគេហៅថាហត់ឡាយ ឬ ថូលហ្វ្រី

មានលេខទូរស័ព្ទខ្លះ ដែលលោកអ្នកអាចហៅពីចម្ងាយ : ឡុងឌីស្ទិន ដោយឥតបង់លុយៗ ឧ. ចង់ទាក់ទងរកពត៌មាន សំរាប់ធ្វើការណែនាំ សូមទាក់ទង លេខ១៨០០-៤២៤-៣៧០១។ ទូរស័ព្ទណាដែលមានលេខ១៨០០ចាប់ផ្តើម គឺជាទូរស័ព្ទឥតបង់លុយ។

តេឡេក្រាម

បើសិនជាលោកអ្នក ត្រូវការបញ្ជូនដំណឹងប្រញាប់ លោកអ្នកអាចផ្ញើរតេឡេក្រាមៗ លោកអ្នកអាចផ្ញើរតេឡេក្រាម ដោយនិយាយទូរស័ព្ទទៅកន្លែងផ្ញើរតេឡេក្រាម និយាយប្រាប់ពត៌មាន ដែលលោកអ្នកត្រូវផ្ញើរ ហើយនិងប្រាប់អស័យដ្ឋានអ្នកទទួល។ លោកអ្នកអាចផ្ញើរប្រាក់ទៅឲ្យអ្នកម្ខាងទៀត តាមការិយាល័យតេឡេក្រាមបានដែរ។

ការផ្ញើរដំណឹងតាមតេឡេក្រាម អស់ប្រាក់ច្រើនជាងផ្ញើរសំបុត្រ។

ការធ្វើដំណើរនិងការទាក់ទងគ្នា

ពេលលោកអ្នកមកដល់សហរដ្ឋអាមេរិកភ្លាម លោកអ្នកគួរហាត់ធ្វើដូចតទៅនេះ :

- រៀនជិះយានសាធារណៈ ដូចជា ឡានប៊ីស រថភ្លើងក្នុងដីដែលគេហៅថា ស៊ើបវេ (Subway) រថភ្លើង...។ល។
- សួរគេ ពីរបៀប ឬច្បាប់ដើរឆ្លងផ្លូវ ច្បាប់ជិះកង់ និងច្បាប់បើករថយន្ត។
- រៀនគោលការណ៍សន្តិសុខចរាចរណ៍ របៀបបើករថយន្ត ឲ្យបានសុខ និងរៀនរបៀបចៀសវាងគ្រោះថ្នាក់។
- រៀនហៅរថយន្តពេទ្យពេលមានអាសន្ន (Ambulance) ។
- ដឹងរបៀបសុំច្បាប់ ប្រលងយកច្បាប់អនុញ្ញាតិបើកបរ។
- ដឹងរបៀបសុំឲ្យក្រុមហ៊ុនដាក់ទូរស័ព្ទ និងរបៀបបង់ថ្លៃកក់។
- ដឹងពីទីកន្លែងដែលមានទូរស័ព្ទសំរាប់សាធារណជនប្រើ និងដឹងពីរបៀបប្រើ។
- ដឹងពីរបៀបទូរស័ព្ទ ហៅរកឲ្យគេជួយ នៅពេលមានអាសន្ន។
- លោកអ្នកនិងសមាជិកទាំងអស់ ត្រូវដឹងឲ្យពិតប្រាកដ និងចាំពីអស័យដ្ឋាននិងលេខទូរស័ព្ទរបស់ខ្លួន ទុកសំរាប់ពេលមានអាសន្ន ត្រូវយកក្រដាសដែលមានអស័យដ្ឋាននិងលេខទូរស័ព្ទ ទៅជាមួយជានិច្ច។
- ត្រូវដឹងទូរស័ព្ទមួយណាដែលហៅទៅ ឥតបង់ថ្លៃ និងមួយណាអស់លុយ។
- ដឹងពីរបៀបផ្ញើរសំបុត្រ និងតំលៃ។
- ដឹងពីរបៀបផ្ញើរតេលេក្រាម។



បញ្ជីអត្ថបទ

រឿងរបស់លោក "ក" ៣៧
ការងារនៅសហរដ្ឋ ៣៨
ក្មេងក៏ធ្វើការដែរ ៣៩
មនុស្សចាស់ក៏នៅតែធ្វើការ ៤០
ជំនួយដល់អ្នកដែលខ្វះខាត ៤០
របៀបធ្វើការ ៤១
    អ្នកធ្វើការតាមមុខការជំនាញ ៤១
    អ្នកជំនាញការ ៤២
    អ្នករដ្ឋការ ៤៣
    ធ្វើការពេញម៉ោង ៤៤
    ធ្វើការពាក់កណ្តាលម៉ោង ៤៤
ការរកការងារធ្វើ ៤៥
    មិត្តនិងអ្នកអាណាព្យាបាល ៤៥
    ការិយាល័យផ្តល់សំរាប់រកការងារធ្វើ ៤៥
    លពាក្យនៅតាមអាគារ ៤៦
    ការសែត ៤៦
    ភ្នាក់ងាររកការងារធ្វើរបស់ឯកជន ៤៦
ការដាក់ពាក្យសុំធ្វើការ ៤៧
    Social security and I-94 .... ៤៧
    លិខិតប្រវត្តិរូប ៤៨
    ការធ្វើសម្ភាសន៍ ៤៩
ការទទួលខុសត្រូវការងារនិងប្រាក់បំណាច់ ៥១
    ម៉ោងធ្វើការ ៥១
    ច្បាប់របស់ក្រុមហ៊ុន ៥១
    ប្រាក់បំណាច់បន្ថែម ៥១
    នៅពេលធ្វើការ ៥២
    នាឡិកាចុចម៉ោង ៥២
    ការប្រើទូរស័ព្ទ ៥២
    រយៈពេលសាកល្បង ៥២
    ការបើកប្រាក់ខែ ៥៣
    ឆែក ៥៣
    ការបើកប្រាក់ ៥៤
    សហជីពនិងភាជីវៈសង្គម ៥៤
ការតំឡើងមុខការឱ្យរឹតតែប្រសើរ ៥៥
    ការសិក្សាជំនាញការ ៥៥
        - កម្មវិធីសិក្សាសំរាប់មនុស្សធំ ៥៦
        - មហាវិទ្យាល័យសហគមន៍ ៥៦
        - សាលាសិក្សាមុខរបរនិងបច្ចេកទេស ៥៦
        - សាលាឯកជន ៥៦
        - ស៊ីតា ៥៧
        - ចបខប(Job corps) ៥៨
ការផ្លាស់ប្តូរការងារ ៥៩
គំរូលិខិតសុំការធ្វើ ៦០
លេខទូរស័ព្ទសំខាន់ៗ ៦១

រឿងរបស់លោក "ក"

លោក "ក" ជាតាយទាហានមួយរូប កាលពីនៅស្រុកខ្មែរ។ ឥឡូវនេះ នៅក្នុងសហរដ្ឋ លោកជាអ្នកមើលថែទាំសំអាត នៅសាលាបឋមសិក្សា។ លោកមានការតប់ប្រមល់ធុញថប់ជាខ្លាំងនឹងការងារនេះ ប៉ុន្តែលោកមិនដឹងធ្វើយ៉ាងដូចម្តេច។ ដោយអ្នកអាណាព្យាបាលលោករកការងារនេះឲ្យលោកធ្វើ លោក "ក" មិនហ៊ានប្រាប់អ្នកអាណាព្យាបាលថា លោកមិនចូលចិត្តការងារនេះឡើយ ដោយខ្លាចក្រែងអ្នកអាណាព្យាបាលនិយាយថា លោករើសទទឹង។ លោកមិនហ៊ានរកការណាផ្សេងទៀតឡើយ។

លោក "ក" គិតថា លោកជាប់អន្ទាក់ហើយ។ លោកក៏ឈប់រវីរវល់នឹងអ្នកឯទៀត។ មិត្តរបស់លោកម្នាក់ មានការបារម្ភក្នុងរឿងនេះ ហើយបានទៅពិគ្រោះនឹងសមាគមខ្មែរ។

លោក "គ" ធ្វើការនៅសមាគម បានពិភាក្សាជាមួយលោក "ក" ហើយបានអះអាងថា នឹងពន្យល់អ្នកអាណាព្យាបាលឲ្យយល់ពីគោលបំណងរបស់លោក "ក" ដែលចង់រកការងារឲ្យបានប្រសើរជាងសព្វថ្ងៃ។ លោក "គ" និងលោក "ក" ពិភាក្សាគ្នាឃើញថា លោក "ក" គួររៀនអង់គ្លេសបន្ថែមទៀត។ ពីរ-បីអាទិត្យក្រោយមក លោក "គ" បានរកថ្នាក់ឲ្យលោក "ក" បានចូលរៀន ថ្វីត្បិតតែថ្នាក់នីមួយៗ មានសិស្សរង់ចាំក៏ដោយ។

លោក "ក" បានធ្វើការផង (ពាក់កណ្ដាល) រៀនភាសាអង់គ្លេស និង រៀនកុំព្យូទ័រ (Computer) ផង។ ពេលលោករៀនចប់ សាលាបានជួយលោក ក្នុងការរកការងារធ្វើ។ ឥឡូវនេះ លោកបានការមួយដែលលោកពេញចិត្តថា នឹងមានអនាគត។

ក្មេងក៏ធ្វើការដែរ

ជាការធម្មតាទេ ចំពោះអាមេរិកាំង ដែលគេឲ្យកូនគេធ្វើការជុំវិញផ្ទះៗ រាល់ថ្ងៃ មុនពេលទៅសាលា ឬក្រោយពេលចេញពីសាលា ក្មេងៗខ្លះអាយុពី ១០ ទៅ១៥ឆ្នាំ អាចដើរលក់កាសែតៗ ក្មេងៗធំៗធ្វើការពាក់កណ្ដាលពេលៗ គេធ្វើការក្រោយពេលចេញពីសាលារៀន នៅថ្ងៃសៅរ៍ចុងសប្ដាហ៍ ឬ ក្នុងពេលឈប់សំរាកៗ នៅពេលធ្វើការ ក្មេងអាចយល់ពីតំលៃការងារ ទោះជាការងារនោះ ធ្វើដោយកំលាំងដៃក៏ដោយៗ មិនតែប៉ុណ្ណោះ ក្មេងអាចចេះសន្សំប្រាក់កាស និងទុកចិត្តក្នុងការកសាងជីវិតៗ

ក្មេងៗដើរចែកកាសែតពេលព្រឹក

មនុស្សចាស់ក៏នៅតែធ្វើការដែរ

អាមេរិកាំងជឿថា មនុស្សគួរតែធ្វើការ បើគេអាចធ្វើការបាន។ អាមេរិកាំងជាច្រើន មិនយល់ស្រប នឹងគំនិត ដែលថាឈប់ធ្វើការនៅពេលអាយុ៦៥ឆ្នាំ ដោយគេនៅតែបន្តធ្វើការ ប្រសិនបើគេមានសុខភាពល្អ។

ជំនួយដល់អ្នកដែលខ្វះខាត

អាមេរិកាំងភាគច្រើនយល់ដែរថា មនុស្សខ្លះត្រូវការជំនួយពីគេ។ មនុស្សទាំងនេះមាន មនុស្សដែលពិការ ឬ មានជម្ងឺសតិ ឬ ចាស់ធ្វើការមិនកើត ឬ ឪពុកម្ដាយដែលមានកូនច្រើន ត្រូវការប្រាក់ជំនួយ ដើម្បីចិញ្ចឹមកូន។ ប្រាក់ជំនួយនេះ ហៅថា វែលហ្វែរ ដែលជាប្រាក់ជំនួយផ្សេងៗ ផ្ដល់ដោយរដ្ឋាភិបាល ដល់អ្នកដែលត្រូវការ។ លុយវែលហ្វែរនេះ បានមកពីប្រាក់ពន្ធដែលអ្នកធ្វើការ បង់ឲ្យទៅរដ្ឋាភិបាល។

ដោយសារការឲ្យតម្លៃការងារជាងការយកលុយវែលហ្វែរ ទើបអ្នកអាណាព្យាបាល អង្គការមនុស្សធម៌ និងអាមេរិកាំងផ្សេងទៀត ជំរុញឲ្យលោកអ្នកធ្វើការក្នុងពេលឆាប់ៗ គេសង្ឃឹមថា លោកអ្នកនឹងព្យាយាមធ្វើការងារនេះ រហូតទាល់លោកអ្នកអាចរកបានការធ្វើជាងមុន។ គេនឹងមិនចូលចិត្តទេ បើលោកអ្នកជំទាស់នឹងការធ្វើការងារ ឬ បោះបង់ការងារ ហើយពឹងផ្អែកតែលើប្រាក់វែលហ្វែរ។

អ្នកបំរើតុកំពុងលាងចាន

អ្នកធ្វើការគ្មានមុខការជំនាញ

មុខការដែលមិនចាំបាច់ត្រូវប្រើចំណេះវិជ្ជាស្ទាត់ជំនាញ នោះគឺៈ អ្នកថែទាំអាគារនានា អ្នកលាងចាន អ្នកបំរើតុៗ ការងារនេះស្រួលរក ពីព្រោះ វាមិនចាំបាច់ត្រូវការការស្ទាត់ជំនាញ និងការចេះនិយាយភាសាអង់គ្លេសជ្រៅជ្រះៗ តាមធម្មតា លោកអ្នកនឹងបានកំរៃប្រចាំម៉ោងតិចបំផុតនៃតំលៃការងារ នៅសហរដ្ឋគឺ $ 3.35 ក្នុង១ម៉ោង នៅខែមករា១៩៨១។ អ្នកភៀសខ្លួនភាគច្រើន ធ្វើការនេះផង សិក្សាភាសាអង់គ្លេសផង ឬ មុខវិជ្ជាជំនាញ ក្នុងពេលជាមួយគ្នា ហើយសង្ឃឹមថា គេអាចរកបានការងារល្អធ្វើៗ

អ្នកជំនាញការ

មុខការត្រូវការវិជ្ជាស្ទាត់ជំនាញគឺៈ ជាងឡាន ជាងបំពង់ទឹកឬឧស្ម័ន ជាងធ្វើសក់ អ្នកវាយអង្គុលីលេខៗ ការងារទាំងនេះ ត្រូវការហាត់ហ្វឹកហ្វឺន ចេះភាសាអង់គ្លេស ជ្រៅជ្រះ ហើយប្រាក់ខែ តិចឬច្រើនអាស្រ័យលើការពិសោធន៍របស់អ្នកធ្វើការៗ ប្រាក់ឈ្នួលរបស់ជាងបំពង់ទឹក ឬ ឧស្ម័ន ច្រើនជាងប្រាក់ឈ្នួលរបស់អ្នកធ្វើការ នៅការិយាល័យទៅទៀតៗ

អ្នកធ្វើការមានជំនាញការ ដូចជាៈ អ្នកធ្វើសក់ ខាងលើ អ្នកវាយអង្គុលីលេខ ខាងក្រោម អ្នកធ្វើឡាន ខាងស្តាំ

អ្នករដ្ឋការ

អ្នករដ្ឋការគឺ គ្រូបង្រៀន វិស្វករ វេជ្ជបណ្ឌិត មេធាវីៗ ការងារទាំងនេះ ត្រូវការយ៉ាងតិចណាស់មាន សញ្ញាប័ត្រពីមហាវិទ្យាល័យ។ រដ្ឋនីមួយៗមានច្បាប់ផ្ទាល់ ដែលកំរិតការហាត់ហ្វឹកហ្វឺនវិជ្ជាជីវៈ។ ឧទាហរណ៍ វេជ្ជបណ្ឌិត ម្នាក់ចង់ធ្វើការរបស់ខ្លួនក្នុងរដ្ឋមួយថ្មីទៀត ត្រូវប្រឡង ដើម្បីយកសញ្ញាប័ត្រ ដែលបញ្ជាក់ដោយរដ្ឋនោះៗ

នៅសហរដ្ឋ មនុស្សម្នាក់ អាចធ្វើការពេញម៉ោង ឬ ពាក់កណ្ដាលម៉ោង ដោយពឹងផ្អែកទៅលើការងារ បញ្ហាគ្រួសារ និង បញ្ហាផ្សេងៗទៀត។

គ្រូកំពុងតែបង្រៀន ខាងឆ្វេង
ឱសថការីសរសេរលិខិតបញ្ជា កំពុងលាយថ្នាំ ខាងស្ដាំ

ធ្វើការពេញម៉ោង

ជាទូទៅ ការធ្វើការពេញម៉ោងគឺរវាង ៣៥ ទៅ ៤០ម៉ោង ក្នុងមួយអាទិត្យ។ ការងារជាប្រចាំនៅសហរដ្ឋ ធ្វើការពីម៉ោង ៩:០០ព្រឹក ទៅម៉ោង ៥:០០ល្ងាច ពីថ្ងៃចន្ទទៅដល់ថ្ងៃសុក្រ។ ហាងលក់ទំនិញ រោងចក្រ ភោជនីយដ្ឋាន តែងមានវេនធ្វើការផ្លាស់ប្តូរគ្នា ជួនកាលធ្វើយប់ ជួនកាលធ្វើថ្ងៃ ឬ ធ្វើបន្ថែមម៉ោង។

ការងារនៅចង្ក្រានបាយ

ធ្វើការពាក់កណ្តាលម៉ោង

ម៉ោងធ្វើការនៃការងារពាក់កណ្តាលម៉ោង ប្រែប្រួលទៅតាមការងារខ្លួនឯង តាមទីកន្លែងធ្វើការ និង ម្ចាស់ហាង។ គេអាចធ្វើ ២ ឬ ៣ ម៉ោង ឬ រហូតដល់ ៣៥ ម៉ោងក្នុងមួយអាទិត្យ។ ការងារពាក់កណ្តាលម៉ោង អាចផ្លាស់ប្តូរពេលបាន ដែលអាចឲ្យគេធ្វើសកម្មភាពផ្សេងៗ បាននៅពេលធ្វើការផង ដូចជា ទៅសាលារៀននៅថ្ងៃខ្លះ និង ធ្វើការនៅថ្ងៃផ្សេងទៀត។

មិត្ត និង អ្នកអាណាព្យាបាល

អ្នកភៀសខ្លួនភាគច្រើន ដែលរកការធ្វើ ដោយសារ ជំនួយខាងពីមិត្ត ឬ អ្នកអាណាព្យាបាល ឬ អ្នកស្គាល់ៗ សមាគមខ្មែរនិងភ្នាក់ងារមនុស្សធម៌អាចជួយលោកអ្នកស្វែងរកការធ្វើ។

ការិយាល័យសំរាប់រកការឲ្យធ្វើ

ការិយាល័យសំរាប់រកការឲ្យធ្វើ នឹងជួយលោកអ្នកស្វែងរកការធ្វើ។ ពេលលោកអ្នកដាក់ពាក្យសុំធ្វើការ គេនឹងជួយលោកអ្នក ហើយនឹងប្រាប់ពីការងារ ដែលលោកអ្នកអាចធ្វើបាន ក្នុងតំបន់លោកអ្នករស់នៅៗ នៅពេលលោកអ្នករង់ចាំ គេអាចជួយរកសាលាសិក្សាភាសាអង់គ្លេស ឬ មុខវិជ្ជាជំនាញណាមួយ ឲ្យលោកអ្នកសិក្សា។

ការពិភាក្សានៅការិយាល័យជួយរកការឲ្យធ្វើ

សញ្ញាទៅតាមអាគារ

ដំណឹងការងារអាចមាន បិទផ្សាយនៅតាមបណ្ណាល័យ សាធារណៈ ក្រុមហ៊ុនធំៗ និងការិយាល័យរបស់រដ្ឋ។ ភាគនិយមន៍ជាច្រើនដាក់ សញ្ញា HELP WANTED (ត្រូវការអ្នកធ្វើការ)។ ប្រសិនបើលោកអ្នកមាន បំណងធ្វើការដែលគេបិទនោះ លោកអ្នកអាចទៅទាក់ទង ពិភាក្សាជាមួយអ្នកចាត់ការ នៅទីនោះ។

ភ្នាក់ងាររកការងារធ្វើរបស់ឯកជន

ភ្នាក់ងារនេះ សឹងការងារជាច្រើន ដែល អាចបញ្ជូនលោកអ្នកឲ្យទៅរក ក៏ប៉ុន្តែភ្នាក់ងារ នេះនឹងទារប្រាក់ឈ្នួលពីលោកអ្នក ឬ ពីម្ចាស់ហាង បើ សិនជាលោកអ្នករកបានការធ្វើ។ មុននឹងឲ្យភ្នាក់ងារ នេះរកការងារធ្វើ អ្នកត្រូវសួរពីលក្ខខណ្ឌ ពីកិច្ច សន្យាដោយប្រយ័ត្នប្រយែង។

កាសែត

សារព័ត៌មានភាគច្រើន មានចុះផ្សាយពីមុខការដែល ទំនេរ តាមលេខរៀងអក្សរនៃមុខការ។ ដូចជា អ្នកលាង ចាន ជាងទង អ្នកវាយអង្គុលីលេខ។ ការចុះផ្សាយនីមួយៗ តែងតែមានអធិប្បាយពីការងារ ប្រាក់ខែ ព្រមទាំងមាន លេខទូរស័ព្ទ ឬ អស័យដ្ឋានដែលអ្នកអាចទូរស័ព្ទទៅ ឬ សរសេរ សំបុត្រទាក់ទងសុំការធ្វើ។

ការដាក់ពាក្យសុំធ្វើការ

Social Security Card and I-94

ដើម្បីធ្វើការ នៅក្នុងសហរដ្ឋ លោកអ្នកត្រូវមាន Social Security Number ។ ជនភៀសខ្លួនទាំងអស់ គួរស្នើសុំ Social Security Number នៅពេលមកដល់សហរដ្ឋអាមេរិកភ្លាម សូម្បីតែអ្នកមិនទាន់រកការធ្វើក៏ដោយ។

អ្នកអាចសុំ Social Security Number នៅ Social Security Office ។ មិត្ត ឬ អ្នកអាណាព្យាបាលរបស់លោកអ្នក អាចជួយលោកអ្នក ក្នុងការសុំប័ណ្ណនេះ។

លោកអ្នកត្រូវកាន់ប័ណ្ណនេះរហូត ថ្វីបើលោកអ្នករៀបការ ប្តូរការងារ ឬ ប្តូរឈ្មោះក៏ដោយ។ ពេលលោកអ្នកស្នើសុំការធ្វើ លោកអ្នកត្រូវយក Social Security Number និង I-94 ទៅជាមួយ។ ប័ណ្ណទាំងពីរនេះបញ្ជាក់ថា លោកអ្នកមានសិទ្ធិធ្វើការបាននៅក្នុងសហរដ្ឋ។

លិខិតប្រវត្តិរូប

មុនពេលលោកអ្នករកការធ្វើ លោកអ្នកគួរសរសេរលិខិតប្រវត្តិរូប ដែលផ្តល់ពត៌មានពីខ្លួនលោកអ្នក និង ការពិសោធន៍របស់លោកអ្នក។ ការនេះអាចជួយលោកអ្នក ក្នុងការបំពេញសំណុំលិខិតសុំការធ្វើ។ ជួនកាល លោកអ្នកអាចផ្ញើរលិខិតប្រវត្តិរូបភ្ជាប់ជាមួយលិខិតសុំការធ្វើ។ ផ្លាស់ប្តូរទៅតាមមុខការ ដែលលោកអ្នកស្វែងរក ប្រវត្តិរូបលោកអ្នកមានពត៌មានដូចខាងក្រោមនេះ :

- ឈ្មោះ អស័យដ្ឋាន និង លេខទូរស័ព្ទរបស់លោកអ្នក។
- Social Security Number និង I - 94 របស់លោកអ្នក(សំខាន់)។
- ឈ្មោះ អស័យដ្ឋាន របស់ម្ចាស់ហាងដែលលោកអ្នកធ្វើការពីមុន។
- ប្រវត្តិប្រាក់ខែរបស់លោកអ្នក ថ្ងៃចូលធ្វើការ និងការអធិប្បាយសង្ខេបពីមុខងាររបស់លោកអ្នក។
- សាលាដែលបានទៅរៀន រួមទាំងពេលសិក្សាហ្វឹកហ្វឺនក្នុងពេលវិស្សមកាល ថ្ងៃចូលរៀន និង សញ្ញាប័ត្រ។
- សំបុត្របញ្ជាក់ផ្ដាំផ្ញើរ ជាមួយឈ្មោះ អស័យដ្ឋាន និងលេខទូរស័ព្ទ។
- ការពិសោធន៍ផ្សេងៗ មានទាំងសកម្មភាពស្ម័គ្រចិត្តធ្វើការផ្សេងៗ ជាមួយសហគមន៍ វិហារគ្រិះ ឬ ជំរុំ។

ការធ្វើសម្ភាសន៍

ពេលស្វែងរកការធ្វើ ដំបូងលោកអ្នកគួរទាក់ទងម្ចាស់ហាង ឬ អ្នកតំណាង។ ការទាក់ទងទាំងនេះ អាចធ្វើតាមទូរស័ព្ទ។ មិត្ត ឬ អ្នកអាណាព្យាបាល អាចជួយលោកអ្នកដើម្បីធ្វើការណាត់ជួបនេះ។ ការងារភាគច្រើន ត្រូវការធ្វើសម្ភាសន៍។ ការធ្វើសម្ភាសន៍ ធ្វើឡើងរវាងម្ចាស់ហាង និង ខ្លួនលោកអ្នកផ្ទាល់។

ពិនិត្យលិខិតប្រវត្តិរូបជាថ្មី នៅពេលធ្វើសម្ភាសន៍

ពេលពិភាក្សានេះ គេនឹងសួរលោកអ្នក នូវសំណួរជាច្រើនដើម្បីឱ្យដឹងថា តើលោកអ្នកមានសមត្ថភាពអាចទទួលការងារធ្វើ ឬទទួលស្គាល់ជាអ្នកធ្វើការ គួរជាទីទុកចិត្តបានឬទេ។ អ្នកធ្វើសម្ភាសន៍នឹងសួរលោកអ្នក តើលោកអ្នកមកនៅសហរដ្ឋពីពេលណា និងពីកន្លែងធ្វើការ និងសាលាដែលអ្នកធ្លាប់រៀនផងដែរ។

ដើម្បីត្រៀមចាំធ្វើសម្ភាសន៍ លោកអ្នកគួរប្រុងប្រៀបសំណួរដែលម្ចាស់ហាងអាចសួរពីការពិសោធន៍ ពីសាវតារ និងការងារចំណូលចិត្តរបស់អ្នក។ បន្ថែមទៀតលោកអ្នកអាចស្វែងរកការងារ ដែលលោកអ្នកស្នើសុំ ហើយធ្វើឱ្យអ្នកធ្វើសម្ភាសន៍យល់ថា លោកអ្នកមានសមត្ថភាពអាចទទួលការងារនេះបាន។

មុនពេលទៅធ្វើសម្ភាសន៍ លោកអ្នកគួរចងចាំធ្វើដូចខាងក្រោមនេះ :

- ទៅឱ្យទាន់ពេល

មិនត្រូវទៅមុនម៉ោងពេក ឬ យឺតពេក។ លោកអ្នកគួរទុកពេល ឱ្យទៅដល់កន្លែងណាត់ជួប មុនពេលធ្វើសម្ភាសន៍៥នាទី។ ជនជាតិអាមេរិកាំង ឱ្យតម្លៃយ៉ាងខ្ពស់ ចំពោះការគោរពពេលវេលា។

- ស្លៀកពាក់ស្អាតបាត

លោកអ្នកត្រូវស្លៀកពាក់ឲ្យបានស្អាតបាត នៅពេលទៅធ្វើសម្ភាសន៍។ លោកអ្នកអាចសួរមិត្ត ឬ អ្នកអាណាព្យាបាលអ្នក ពីសំលៀកបំពាក់ដែលលោកអ្នកគួរស្លៀក។

- នាំអ្នកបកប្រែទៅជាមួយ បើសិនជាចាំបាច់

- ប្រវត្តិរូប

